# ភាពៈមេដឹកនាំ

## LEADERSHIP

*ផ្លូវណាដែលមេដឹកនាំខ្មែរគួរធ្វើដំណើរ ?*

### សេចក្តីប្រារព្ធ

មនុស្សកើតមកប្រកបដោយសិទ្ធិសេរីភាពខាងគំនិតនិងការបដិបត្តិជាច្រើនជាពិសេសសំរាប់មេដឹកនាំដែលជាបុគ្គលសំខាន់គំរូគេ នាំមុខគេ ក្នុងការកំណត់ជោគវាសនារបស់ប្រជាជនភាគច្រើន ដូច្នេះ តើមេដឹកនាំខ្មែរគួរជ្រើសរើសយកផ្លូវមួយណា?។ ជាការចាំបាច់ណាស់បើមេដឹកនាំខ្មែរទាំងអស់ឬយុវជនខ្មែរជំនាន់ក្រោយ ដែលនឹងក្លាយទៅជាមេដឹកនាំនាពេលអនាគត់នោះ ប្រឹងស្វែងយល់យកផ្លូវដែលត្រឹមត្រូវមួយ និងសិក្សាយកគំរូល្អៗតាមមេដឹកនាំរបស់ខ្មែរយើងពីអតីតកាល ព្រមទាំងមេដឹកនាំល្បីៗក្នុងពិភពលោកយើងនេះ។ អត្ថបទនេះគ្រាន់តែជាអនុសាសន៏និងជាពន្លឺខ្លះៗសំរាប់មេដឹកនាំខ្មែរទាំងអស់ ជាពិសេសគឺយុវជនខ្មែរជំនាន់ក្រោយតែប៉ុណ្ណោះ ។

### ភាពចាំបាច់សំរាប់ភាវៈជាមេដឹកនាំ

មេដឹកនាំឬអ្នកដឹកនាំ ជាគោលការណ៏មួយដែលមនុស្សម្នាក់ៗត្រូវតែព្យាយាមស្វែងរកមកទុកក្នុងក្រអៅបេះដូងរៀងៗខ្លួន។ បើមនុស្សម្នាក់ៗខ្វះភាវៈជាមេដឹកនាំនៅក្នុងចិត្តហើយ គេពិបាកនឹងធ្វើជីវិតឲ្យចំរើនរុងរឿងខ្លាំងណាស់។ ខ្មែរយើងភាគច្រើនតែងយល់ថា ភាវៈមេដឹកនាំគឺមានសំរាប់តែប្រមុខរដ្ឋឬអ្នកនយោបាយមួយក្រុមតូចប៉ុណ្ណោះ។ ជាការជាក់ស្តែងប្រទេសដែលប្រកាន់យកលទ្ធិផ្តាច់ការ ប្រទេសជាតិទាំងមូលនឹងគ្រប់គ្រងទាំងស្រុងដោយមនុស្សមួយក្រុមតូច។ តែសំរាប់យុគបច្ចុប្បន្នជាយុគត្រាស់ដឹង(Enlightenment Era) បុគ្គលម្នាក់ៗនៅក្នុងប្រទេសមួយៗគឺជាមេដឹកនាំ។ រាប់ចាប់តាំងពីសមាជិកម្នាក់ៗក្នុងសង្គម

គ្រួសារ ភូមិ ស្រុក ខេត្ត ក្រុង និងប្រទេស ត្រូវតែអភិវឌ្ឍន៍ភាវៈដឹកនាំឲ្យមាននៅក្នុងខ្លួនដើម្បីជាភ្នែកប្រមុះក្នុងការអភិវឌ្ឍន៍សង្គមរួមគ្នានូវគ្រប់វិស័យ។ តែទោះជាយ៉ាងណាក៏ដោយ ឋានៈជាអ្នកដឹកនាំក្នុងគ្រួសារនិងអ្នកដឹកនាំសង្គមជាតិទាំងមូលមានភាពខុសគ្នាឆ្ងាយណាស់ព្រោះផលប៉ះទង្គិចពីការដឹកនាំខុស ដឹកនាំជ្រុល មានទំហំខុសគ្នាខ្លាំងណាស់ ។

នៅក្នុងសៀវភៅសកលចិន្តារបស់ព្រះភិក្ខុធម្មបាលខៀវ ជុំ ភាគ២ ត្រង់ទំព័រ៤៣៣ បានបញ្ជាក់ថា "សង្គ្រាមជាហេតុធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍន៍សង្គម ប៉ុន្តែបើមេដឹកនាំគ្មានសមត្ថភាព គ្មានគំនិតសង្គម គ្មានស្មារតីយុត្តិធម៌។ល។ ចាត់ការគ្រប់គ្រងប្រទេសគ្មានប្រសិទ្ធិភាព ប្រជាពលរដ្ឋស្តាប់មិនបាន មើលមិនយល់ មិនដឹងជាអ្នកដឹកនាំដឹកដៃខ្លួនចង់ដើរផ្លូវណា?។ ព្រឹត្តិការណ៍ស្រុកទេសមានសភាពដូចនេះ កំរនឹងគេចផុតពីអនាធិបតេយ្យគឺភាពវឹកវរចលាចល។ ជាពិសេសភាពអារាត់អារាយស្តាប់គ្នាលែងកើតវាងអ្នកដឹកនាំនិងអ្នកដើរតាមនេះជាកត្តាមួយទៀតដែលធ្វើឲ្យការអភិវឌ្ឍន៍ចេញមិនរួច។ បុព្វហេតុនៃការគ្មានសណ្តាប់ធ្នាប់ដែលជាធាតុជាន់ពន្លិចការអភិវឌ្ឍន៍ គ្មានមកពីអ្នកណាដទៃទេ គឺមកពីអ្នកគ្រប់គ្រងគ្មានសមត្ថភាព ធ្វើចំណាត់ការសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច វប្បធម៌ គ្មានប្រសិទ្ធិភាពហ្នឹងឯង" ។

**និយមន័យពាក្យថា "អ្នកដឹកនាំ"**

ភាសាខ្មែរយើងមានពាក្យជាច្រើនដែលប្រើបញ្ជាក់អត្ថន័យជាអ្នកដឹកនាំដូចជា មេ ប្រធាន នាយក ប្រមុខ ចៅហ្វាយ និង រាជា ជាដើម ។

នៅក្នុងវចនានុក្រមទាំងពីរភាគរបស់សម្តេចព្រះសង្ឃរាជជួន ណាត បានឲ្យនិយមន័យពាក្យទាំងអស់នេះដូចតទៅ

មេ មានន័យថា មនុស្ស សត្វ ឬអ្វីៗដែលដែលជាធំ ជាប្រធាន ជាចម្បងលើគេ

ប្រធាន មានន័យថា មេ, អ្នកដែលជាមេលើគេ, ដែលជាធំជាងគេ

នាយក មានន័យថា អ្នកនាំ, អ្នកដឹកនាំ, អ្នកត្រួតត្រា

ប្រមុខ មានន័យថា ដែលជាប្រធាន, ជាធំបំផុត, ចម្បង, ដែលប្រសើរក្រៃលែង, ដែលជាឯក ជាទី១

ចៅហ្វាយ មានន័យថា អ្នកដែលជាម្ចាស់, ជាអ្នកនាយកលើគេ ឬអ្នកដែលត្រួតត្រាការនីមួយៗ ជាធំជាងអ្នកទាំងអស់ក្នុងពួកនោះៗ

រាជា មកពីពាក្យរាជ មានន័យតាមរូបសព្ទថា អ្នករុងរឿងដោយវិសេសព្រោះមានតេជៈក្រៃលែង ឬប្រែថា អ្នកញ៉ាំងប្រជាពលរដ្ឋ គឺគ្រប់គ្រងប្រជានិករឲ្យមានស្វាមីភក្តិចំពោះព្រះអង្គ ព្រោះព្រះអង្គមានសង្គហធម៌៤យ៉ាងគឺការឲ្យទេយ្យវត្ថុ, ការពោលវាចាគួរឲ្យចង់ស្តាប់, ការប្រព្រឹត្តអំពើជាប្រយោជន៍, ការតាំងព្រះអង្គស្មើៗ គឺប្រើឫកពាឲ្យល្មមពេញចិត្តប្រជារាស្ត្រ ។

ទាំងពាក្យ មេ ប្រធាន នាយក ប្រមុខ ចៅហ្វាយ និង រាជា ជានិច្ចជាកាលខ្មែរយើងនិយមហៅថា អ្នកដឹកនាំ ឬថ្នាក់ដឹកនាំ ឬដោយន័យតាមនាមសព្ទប្រែថាអ្នកដឹកនាំនោះឯង។ អ្នកដឹកនាំអាចបំបែកជាពីរពាក្យគឺ **អ្នកដឹក** និង **អ្នកនាំ** ។

អ្នកដឹកអាចមានន័យផ្សេងៗពីគ្នាដូចជា

- អូសទាញប្រជាជនឲ្យប្រតិបត្តិត្រឹមត្រូវតាមគន្លងច្បាប់នៃរដ្ឋ មានច្បាប់រដ្ឋធម្មនុញ្ញជាដើម ដោយយកខ្លួនឯងជាបង្គោលជាគំរូ ដូចយើងដឹកគោឲ្យដើរត្រង់ផ្លូវទាមទារឲ្យអ្នកដើរមុខត្រូវដើរត្រង់ផ្លូវដែរ ទើបដល់គោលដៅដែលខ្លួនចង់បាន។
- អូសទាញប្រជាជនឲ្យមានសេចក្តីព្យាយាមក្នុងការលះបង់អំពើបាបទាំងពួងដែលមាននៅក្នុងខ្លួន ការពារអំពើបាបមិនឲ្យចូលមកស្ថិតក្នុងខ្លួនទៀត ខិតខំប្រឹងប្រែងធ្វើតែអំពើបុណ្យ និងរក្សាការប្រព្រឹត្តអំពើបុណ្យនោះឲ្យមានការជឿនលឿនទៅមុខ ឬយ៉ាងហោចណាស់រក្សាគុណភាពរបស់វាឲ្យគង់វង្សនៅដដែល ។ល។

ចំណែកអ្នកនាំ គឺអាចមានន័យថា

- នាំប្រជាជនឲ្យសិក្សារឿងច្បាប់ទំនៀមទំលាប់ប្រទេសជាតិឲ្យយល់ច្បាស់ និង អាចយកទៅអនុវត្តបានយ៉ាងមានប្រសិទ្ធិភាព
- នាំប្រជាជនឲ្យយល់អំពីសិទ្ធិសេរីភាពរបស់ខ្លួន ក្នុងនាមជាសមាជិករបស់សង្គម ត្រូវតែមានកាតព្វកិច្ចទទួលខុសត្រូវនិងចូលរួមយ៉ាងសកម្មក្នុងបញ្ហាសង្គមជាតិរបស់ខ្លួន។
- នាំប្រជាជនឲ្យយល់អំពីភាពចាំបាច់ក្នុងការអនុវត្តលទ្ធិប្រជាធិបតេយ្យ ក្នុងការពង្រឹងនិងពង្រីកប្រទេសជាតិឲ្យក្លាយជានីតិរដ្ឋ។ ពេលនីតិរដ្ឋត្រូវបានពង្រឹងនិងពង្រីក ការអភិវឌ្ឍន៍ផ្នែកផ្សេងៗមានសេដ្ឋកិច្ចជាតិជាដើម នឹងរីកចំរើនប្រកបដោយសមភាពនិងភាពថ្លៃថ្នូរប្រាសចាកអំពើពុករលួយនិងការិយាធិបតេយ្យ
- នាំប្រជាជនឲ្យធ្វើតែអំពើល្អ លះបង់នូវអំពើអាក្រក់ និងធ្វើចិត្តឲ្យស្អាតផូរផង់ ។ល។

អ្នកដឹក និង អ្នកនាំអាចមានលក្ខណះការបដិបត្តិខុសគ្នា ព្រោះអ្នកដឹកចាំបាច់ត្រូវតែធ្វើជាគំរូមុនគេឲ្យបានល្អឥតខ្ចោះ ចំណែកអ្នកនាំត្រូវតែមានសមត្ថភាព សុខភាពនិងគុណធម៌ជាចំបង។ យ៉ាងណាក៏ដោយខ្មែរយើងត្រូវតែប្រើពាក្យទាំងពីរនេះជាពាក្យផ្សំរួមគ្នាមិនអាចផ្តាច់ចេញពីគ្នាបានឡើយគឺ **អ្នកដឹកនាំ** ទើបអាចយល់បាន។

## គំរូមេដឹកនាំខ្មែរពីអតីត

តាមប្រវត្តិសាស្ត្រខ្មែរ យើងមានមេដឹកនាំសំខាន់ៗនិងជាគំរូល្អៗជាច្រើនសំរាប់អនុជនខ្មែរយើងជំនាន់ក្រោយបានសិក្សារៀនសូត្រតាម។ ព្រះនាងសក់ក្រអូប(លីវយី)សំគាល់ឃើញថាជាក្សត្រីខ្មែរដំបូងគេ ដែលបានធ្វើខេមរភូបនីយកម្មពីអារិយធម៌ឥណ្ឌាឆ្ពោះទៅរកភាពចំរើនរុងរឿងនៃព្រះរាជាណាចក្ររបស់ព្រះនាង។ ព្រះបាទជ័យវរ្ម័នទីពីរក៏ជាស្តេចខ្មែរ គួរឲ្យកត់

សំគាល់មួយព្រះអង្គដែរ ព្រះអង្គបានទៅធំធាត់និងរៀនសូត្រនៅក្នុងប្រទេសជ្វា(សៃលេន-ទ្របុរ:) តែព្រះអង្គមិនបានស្ថិតក្រោមឥទ្ធិពលរបស់ជ្វាទាំងផ្លូវកាយនិងផ្លូវចិត្តឡើយ។ ព្រះអង្គបានរំដោះប្រទេសកម្ពុជារបស់យើងចេញពីអាណានិគមរបស់ជ្វា ព្រមទាំងកសាងរាជធានីមួយដ៏រុងរឿងឈ្មោះមហេន្ទ្របព្វតាទៀតផង។ ព្រះបាទជ័យវរ្ម័នទី៧ ជាស្តេចអស្ចារ្យរបស់ខ្មែរយើងមួយព្រះអង្គដែរ ដែលពោរពេញទៅដោយមេត្តាករុណានិងបញ្ញាញាណ ព្រះអង្គជាមេដឹកនាំដែលយកធម៌ជាអំណាច និងជាព្រះពោធិសត្វអវលោកេស្វរ:។ នៅសម័យក្រោយអង្គរយើងមានអ្នកតស៊ូដើម្បីជាតិជាច្រើន ដែលបានខិតខំរក្សាទឹកដីយើងសព្វថ្ងៃឲ្យនៅគង់វង្ស ទោះបីយើងជួបប្រទះនូវការព្រុះញង់បំបែកបំបាក់យ៉ាងខ្លាំងពីប្រទេសសៀម និងអណ្ណាម(វៀតណាម) ក៏ដោយ ។

នៅពេលដែលបារាំងចូលមកគ្រប់គ្រងដីខ្មែរ យើងមានព្រះសង្ឃដែលបានសឹកធ្វើជាអាចារ្យនាំប្រជាជនក្រោកឡើងតស៊ូជាមួយអាណានិគមបារាំងដ៏មហិមាជាបន្តបន្ទាប់ ដូចជាអាចារ្យស្វា អាចារ្យពោធិ៍កំបោរ អាចារ្យហៀមចៀវ ជាដើម។ ជាក់ស្តែងអ្នកតាឃ្លាំងមឿងជាមេទ័ពដ៏អង់អាចក្លាហាន នៅពេលដែលដឹងថាកំឡាំងទ័ពរបស់សៀមមានចំនួនច្រើននិងខ្លាំងក្លាជាង សុកចិត្តធ្វើពលិកម្មសំឡាប់ខ្លួនដោយប្រាប់ទៅកងទាហានថា ចូរអ្នកទាំងឡាយខំតស៊ូស្វះស្វែងឡើង ខ្ញុំនឹងទៅប្រមូលកងទ័ពខ្មោចមកជួយច្បាំង។ កងទ័ពទាំងអស់ពេលបានឃើញភាពក្លាហានដើម្បីជាតិដូច្នោះក៏កើតមានភាពកក់ក្តៅនិងកំឡាំងចិត្តខ្លាំងឡើងតស៊ូស្វិតស្វាញរហូតបានជ័យជំនះទៅលើកងទ័ពសៀម។ សម្តេចអង្គដួងជាព្រះមហាក្សត្រខ្មែរដែលសៀមព្យាយាមបំពាក់បំប៉នបណ្តុះមនោគមវិជ្ជាឲ្យមានគំនិតជាសៀម ដោយបានយកទៅចិញ្ចឹមតាំងពីតូចនិងបណ្តុះបណ្តាលឲ្យរៀនសូត្រមានចំណេះដឹងជ្រៅជ្រះ រួចលើកបន្តុបឲ្យឡើងជាព្រះមហាក្សត្រខ្មែរ តែទីបំផុតព្រះអង្គបានរើបំរាស់ចេញពីឥទ្ធិពលសៀមរហូតទទួលបានជោគជ័យ ។

ទាំងនេះជាលក្ខណៈពិសេសរបស់មេដឹកនាំខ្មែរយើងទោះបីជាទទួលការថែទាំនិងគាំទ្រឡើងសក្តិ ពីបរទេសយ៉ាងណាក៏ដោយក៏មិនភ្លេចដើមកំណើតជាតិសាសន៍របស់ខ្លួនឡើយ។

## មេដឹកនាំពីរប្រភេទ

គឺសំដៅយកមេដឹកនាំដែលយកអំណាចជាធម៌ និង មេដឹកនាំដែលយកធម៌ជាអំណាច។ ទាំងពីរយ៉ាងនេះ មានលក្ខណៈខុសគ្នាឆ្ងាយណាស់ ទាំងទ្រឹស្តីនិងបដិបត្តិ។ មេដឹកនាំដែលយកអំណាចជាធម៌ ជានិច្ចជាកាលប្រើអំពើហឹង្សា សំឡុតគំរាមគំហែង ឬប្រើល្បិចកលបោកបញ្ឆោតប្រជាជន ដោយអំពើវិទ្ធង្សនាផ្សេងៗ។ ភាគច្រើននៃមេដឹកនាំដែលយកអំណាចជាធម៌ ជាមនុស្សល្មោភអំណាច អត្តទត្តបុគ្គល និងផ្តាច់ការ ។

ចំណែកមេដឹកនាំដែលល្អ គឺយកធម៌ជាអំណាច យកធម៌ជាត្រីវិស័យក្នុងការកំណត់វាសនារបស់ប្រជារាស្ត្រ។ ធម៌មានន័យច្រើនយ៉ាងដូចជា ច្បាប់ សុក្រិតភាព សេចក្តីល្អមានមេត្តា ករុណា ពលីកម្ម ខន្តី សច្ចៈ និងបញ្ញាជាដើម។ មេដឹកនាំបែបនេះជានិច្ចជាកាលយកភាពត្រឹមត្រូវជាធំក្នុងការសំរេចកិច្ចការទាំងពួងមិនមែនយកអាស្មិមានៈនិងខ្លួនឯងជាធំឡើយ។ ការយកធម៌ជាអំណាចជាការបដិបត្តិត្រឹមត្រូវតាមពុទ្ធដីកា និងជារបបមួយដែលគេស្គាល់ថារបបប្រជាធិបតេយ្យ។ ប្រទេសទាំងឡាយនៅក្នុងសកលលោកសព្វថ្ងៃមានការរីកចំរើនប្រជាជនមានជីវិតរស់នៅស្មើភាព មានសិទ្ធិសេរីភាពក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ការបញ្ចេញមតិ និងបញ្ចេញនូវសមត្ថភាពតែរៀងៗខ្លួន ក្នុងការអភិវឌ្ឍន៍ខ្លួនឯង ក្រុមគ្រួសារ ក៏ដូចជាសង្គមជាតិទាំងមូល ។

## មេដឹកនាំល្អត្រូវប្រកបដោយធម៌ពីរយ៉ាងគឺបិយៈនិងគរុ

ការធ្វើជាមេដឹកនាំល្អត្រូវតែមានព្រហ្មវិហារធម៌គឺមេត្តា ករុណា មុទិតា និងឧបេក្ខា។

សម្តេចព្រះបាទជ័យវរ្ម័នទី៧ ជាស្តេចខ្មែរដ៏អស្ចារ្យដែលព្រះអង្គត្រូវបានប្រជានុរាស្ត្រគោរពប្រៀបប្រដូចទៅនឹងព្រះពោធិសត្វអវលោកេស្វរៈ ដែលមានន័យថាព្រះអង្គសំឡឹងមើលមកក្រោម មករកប្រជានុរាស្ត្ររបស់ព្រះអង្គប្រកបដោយមេត្តាព្រហ្មវិហារធម៌ឥតព្រំដែន។ យើងឃើញកំពូលប្រាង្គបាយន្តមុខបួន ជាភស្តុតាងស្រាប់ ទុកសំរាប់ក្រើនរំលឹកដល់កូនចៅខ្មែរយើងជំនាន់ក្រោយយកគំរូតាម។ ដូចគ្នាដែរមានរឿងព្រេង រឿងដំណាល និងសុភាសិតខ្មែរជាច្រើនដែលជាស់តឿនក្រើនរំលឹកខ្មែរគ្រប់ជំនាន់ឲ្យប្រកាន់ខ្ជាប់ក្នុងក្រអៅបេះដូងនូវព្រហ្មវិហារធម៌៤នេះ។ ជាក់ស្តែងរឿងប្រវត្តិបុណ្យចូលឆ្នាំខ្មែរ ដែលពីមួយឆ្នាំទៅមួយឆ្នាំមានទេវតាព្រះនាមផ្សេងៗ នឹងជាក់ផណគ្នាមកទទួលនិងថែរក្សាក្បាលព្រះព្រហ្ម ដែលជាព្រហ្មវិហារធម៌នោះឯង ។

ព្រហ្មវិហារធម៌នោះប្រកបដោយធម៌ទាំងឡាយដែលមានអង្គ៤គឺ

១.**មេត្តា** មានន័យថាស្រលាញ់ ធម៌ស្រលាញ់នេះ ជាធម៌ដែលមនុស្សម្នាក់ៗត្រូវការជាពិសេសគឺការស្រលាញ់ខ្លួនឯង។ មនុស្សម្នាក់ៗគ្មានស្រលាញ់អ្វីខ្លាំងជាងការស្រលាញ់ខ្លួនឯងឡើយ។ បើដូច្នេះ យើងគួរគិតថា យើងស្រលាញ់ខ្លួនឯងប៉ុណ្ណា គេក៏ស្រលាញ់ខ្លួនគេប៉ុណ្ណោះដែរ។ យើងផ្តល់សេចក្តីស្រលាញ់ដល់ខ្លួនឯងប៉ុណ្ណា យើងក៏គួរផ្តល់សេចក្តីស្រលាញ់ដល់អ្នកដទៃប៉ុណ្ណោះដែរ។ ជាពិសេសមេដឹកនាំគេដែលឱកាសផ្តល់សេចក្តីស្រលាញ់ដល់ខ្លួនឯងមានច្រើន ហើយក៏អាចមានឱកាសផ្តល់សេចក្តីស្រលាញ់ដល់អ្នកដទៃច្រើនដែរ។ តាមច្បាប់នៃធម៌ យើងផ្តល់សេចក្តីស្រលាញ់ដល់អ្នកដទៃច្រើនប៉ុណ្ណា យើងក៏បានទទួលនូវសេចក្តីស្រលាញ់ពីអ្នកដទៃវិញប៉ុណ្ណោះដែរ ។

២.*ករុណា* មានន័យថាអាណិតអាសូរ គ្រាន់តែស្រឡាញ់ខ្លួនឯងឬស្រលាញ់អ្នកដទៃនោះវានៅមិនទាន់គ្រប់គ្រាន់ទេ ត្រូវតែចេះអាណិតខ្លួនឯងនិងអាណិតអ្នកដទៃ។ អាណិតខ្លួនឯងយ៉ាងម៉េច? គឺអាណិតថា ហេតុអ្វីបានជាខ្លួនឯងនៅមានមានៈ ទោសៈ មោហៈ លោភៈ ការខ្ជិលច្រអូស ការមិនចេះដឹងនឹងគេជាដើម។ ការអាណិតអ្នកដទៃក៏ដូចគ្នាដែរ ពេល

ឃើញគេទន់ខ្សោយ យើងជួយគ្រាត្រកង ពេលឃើញគេល្ងង់ យើងជួយបង្ហាត់បង្រៀនណែនាំ ពេលឃើញគេទុក្ខយើងជួយរំលែកទុក្ខជាដើម។ សំរាប់មេដឹកនាំធម៌នេះគឺ សំខាន់ណាស់ ។

៣.**មុទិតា** មានន័យថាជួយឈឺឆ្អាល ជាការបដិបត្តិស៊ីជំរៅនិងពុះពារកាន់តែខ្លាំង ថែមទៀតប្រកបដោយសេចក្តីព្យាយាមទាំងកំឡាំងកាយ ចិត្ត និងប្រាជ្ញា ដើម្បីសន្តោស ប្រណីខ្លួនឯងព្រមទាំងអ្នកដទៃឲ្យចេញផុតពីសេចក្តីទុក្ខលំបាកវេទនា ជាពិសេសមេដឹកនាំ ត្រូវតែជាអ្នកនាំមុខគេក្នុងការជួយខ្នះខ្នែងឈឺឆ្អាលយកអាសារប្រជាជនឲ្យបានរស់នៅមាន ភាពសុខដុមរមនានិងការអភិវឌ្ឍន៍ពិតប្រាកដ មានសេចក្តីសុខទាំងផ្លូវកាយនិងផ្លូវចិត្ត ។

៤.**ឧបេក្ខា** មានន័យថាការតាំងចិត្តជាកណ្តាល ជាផ្លូវកណ្តាល ដោយធ្វើចិត្តឲ្យប្រាស ចាកអគតិបួនយ៉ាងដូចជា មិនអគតិដោយការស្រឡាញ់ ការភ័យខ្លាច ការខឹងស្អប់ និងការ វង្វេងល្ងង់ខ្លៅ។ ការបដិបត្តិធម៌ឧបេក្ខាទាមទារឲ្យយើង ជាពិសេសមេដឹកនាំត្រូវតែប្រឹងប្រែង រៀនសូត្រនិងបដិបត្តិឲ្យខាងតែបាន។ ការមានធម៌ឧបេក្ខាក្នុងចិត្ត គឺប្រៀបប្រដូចនឹងភ្នំដែល មិនញាប់ញ័រដោយកំឡាំងព្យុះសង្ឃរាជាដើម ។

ព្រហ្មវិហារធម៌ទាំងបួន អាចបែងចែកបានជាពីរយ៉ាងគឺ បិយៈដែលមានន័យថាគួរជា ទីស្រឡាញ់ គួរជាទីចូលចិត្តនិងពេញចិត្ត និងគរុ ដែលមានន័យថាគោលជំហររឹងប៉ឹងប្រកប ដោយអំណត់អត់ធន់និងចំណេះដឹងជ្រៅជ្រះ។ បិយៈ មានអង្គប្រកបពីរយ៉ាងគឺមេត្តា និងករុ ណា ចំណែកគរុ មានអង្គប្រកបពីរយ៉ាងដូចគ្នាគឺមុទិតា និង ឧបេក្ខា។ ការដែលយើងមាន មេត្តាគឺសេចក្តីស្រលាញ់មួយដ៏ត្រឹមត្រូវ និងករុណាគឺសេចក្តីអាណិតអាសូរ ដែលចេញពីក្រ អៅបេះដូងពិតប្រាកដ ធ្វើឲ្យយើងម្នាក់ៗទទួលបាននូវការស្រលាញ់ចូលចិត្តពីអ្នកដទៃយ៉ាង ពិតប្រាកដ។ ចំណែកការដែលយើងមានមុទិតាគឺការឈឺឆ្អាលបញ្ចេញសកម្មភាពពិត និង ឧបេក្ខាគឺការមិនមានអគតិនៅក្នុងចិត្ត ជាផ្នែកមួយនៃគោលជំហរគំរូគេប្រកបដោយចំណេះ វិជ្ជា បញ្ញាឈ្លាសវាងវៃ ការតស៊ូនិងការអត់ធន់ នាំឲ្យយើងជាមនុស្សដែលគួរឲ្យគោរពគោរព:

ដែលការគោរពគារវៈនេះ មិនមែនបានមកដោយសារយើងមានលុយកាក់បុណ្យសក្តិនោះទេ តែបានមកដោយសារយើងមានគុណធម៌ ការលះបង់ សមត្ថភាព និងទេពកោសល្យខ្ពស់ ។

អ្នកដឹកនាំ មិនត្រូវគ្រាន់តែធ្វើខ្លួនឲ្យគេស្រលាញ់ចូលចិត្តដោយការតែងខ្លួនស្អាតបាត រូបរាងសង្ហារ សំដីផ្អែម ចេះផ្ញាក់ផ្ញមយកចិត្តអ្នកដទៃ និងមានសន្តានចិត្តល្អប៉ុណ្ណោះទេ តែមេដឹកនាំត្រូវមានគរុនៅក្នុងខ្លួន មានភាពទន់ភ្លន់ប្រកបដោយភាពរឹងប៉ឹងចេញពីខាងក្នុង មានសំដីផ្អែមល្ហែមប្រកបដោយអត្ថរសនិងអត្ថន័យ លំអដោយភាពស្មោះស្ម័គ្រ មានគោលការណ៍ច្បាស់លាស់ប្រដាប់ដោយបញ្ញា បទពិសោធន៍ខ្ពស់ និងចំណេះដឹង។ ជាការចាំបាច់ណាស់សំរាប់មេដឹកនាំ មិនថាឡើយមេដឹកនាំគ្រួសារ មេដឹកនាំសហគមន៍តូចតាច រហូតទៅដល់មេដឹកនាំប្រទេស ត្រូវតែមានគុណសម្បត្តិប្រកបដោយបិយៈនិងគរុនេះឲ្យបាន និងមានតុល្យភាពវាងគ្នានិងគ្នា ។

បើយើងនិយាយបន្ថែមទៅលើធម៌ខ្លះក្នុងព្រះពុទ្ធសាសនាការធ្វើទានដែលត្រឹមត្រូវនិងការរក្សាសីលជាប្រក្រតីចាត់ទុកថាជាការស្វែងរកនូវបិយៈសំរាប់ខ្លួន ហើយការចំរើនភាវនាអភិវឌ្ឍន៍សតិបញ្ញានិងការអំណាត់អត់ធន់ ចាត់ទុកថាជាគរុបានផងដែរ ។

### មេដឹកនាំគួររៀនសូត្រមេរៀនជីវិតបីយ៉ាង(ត្រៃសិក្ខា)

សិក្ខាប្រែសិក្សាដែលជានាទីចាំបាច់របស់មនុស្សម្នាក់ៗ ដែលយើងអាចនិយាយបានថាគ្មាននរណាម្នាក់រស់នៅបានក្នុងលោកនេះឬតែមួយវិនាទីនៃដង្ហើមចេញចូលដោយប្រាសចាកការសិក្សានោះឡើយ។ ជាពិសេសគឺមេដឹកនាំទាំងឡាយត្រូវតែមានចំណេះដឹងគ្រប់បែបយ៉ាងទាំងផ្នែកនយោបាយ សង្គមវិទ្យា ធម្មជាតិវិទ្យា និងចិត្តវិទ្យាជាដើម។ តែក្នុងព្រះពុទ្ធសាសនាព្រះពុទ្ធអង្គសំណូមពរឲ្យយើងរៀនសូត្រមេរៀនបីយ៉ាងប៉ុណ្ណោះ ដើម្បីធ្វើឲ្យជីវិតមានភាពថ្លៃថ្នូរខ្ពង់ខ្ពស់និងអាចរំដោះខ្លួនឲ្យចេញផុតពីបេតវិស័យឬតិរច្ឆានវិស័យ។ មេរៀនបីយ៉ាងនោះគឺសីល សមាធិ និងបញ្ញា ឬមានន័យយ៉ាងសាមញ្ញថាមេរៀននៃការសំដែងចេញនូវកាយវិការ

និងពាក្យសំដីដែលត្រឹមត្រូវ ការរៀបចំផ្នត់គំនិតវិធីគិតនិងសតិសម្បជញ្ញៈដែលត្រឹមត្រូវ និងការយល់ដឹងឈ្លាសវាងវៃប្រកបដោយសុពលភាពខ្ពស់ ។

បើនិយាយឲ្យលំអិតទៅ មេរៀនទាំងបីនេះគឺអរិយមគ្គប្រកបដោយអង្គ៨ ដែលជាវិថីតែមួយគត់អាចនាំមនុស្សលោកទាំងមូលទៅរកសុខសន្តិភាព សេចក្តីចំរើននិងការអស់ទៅនៃទុក្ខទាំងពួងគឺព្រះនិព្វាននោះឯង។ មគ្គប្រកបដោយអង្គ៨នោះបង្រួមជាត្រៃសិក្ខាដូចតទៅនេះគឺ

១.**សីល**(Sila or precepts, morality, ethics) ប្រដាប់ដោយអង្គប្រកប៣យ៉ាងគឺ

- សម្មាវាចា(right speech) គឺវាចាត្រឹមត្រូវ ជាវាចាដែលនិយាយតែពាក្យពិតមិនកុហកបោកប្រាស វាចាដែលនិយាយតែពាក្យញុំាងឲ្យអ្នកដទៃចេះស្រលាញ់យោគយល់គ្នា មិនប្រើពាក្យញុះញង់បំបែកបំបាក់ វាចាដែលនិយាយតែពាក្យទន់ភ្លន់ពីរោះពិសា មិននិយាយពាក្យអសុរោះមិនសមរម្យតាមគតិវិញ្ញូជន និងវាចាដែលនិយាយតែពាក្យមានប្រយោជន៍មានខ្លឹមសារ មិននិយាយពាក្យរោយរាយឥតប្រយោជន៍ច្រើន។ ជាពិសេសសំរាប់មេដឹកនាំ ដែលជានិច្ចជាកាលរមែងស្លាយយកតែពាក្យសំដីប៉ុណ្ណោះទៅបំពេញតួនាទីគ្រប់បែបយ៉ាងរបស់ខ្លួន គួរតែគ្រប់គ្រងវាចារបស់ខ្លួនឲ្យដូចសត្វដីការពារភ្នុករបស់វា។

- សម្មាកម្មន្តៈ(right action) គឺការប្រព្រឹត្តត្រឹមត្រូវដោយកាយ ដោយវាចា និងដោយចិត្ត។ ពេលប្រើប្រាស់កាយ វាចា ចិត្តម្តងៗ ត្រូវតែមានសតិសម្បជញ្ញៈជាប់ជានិច្ច។

- សម្មាអាជីវៈ(right livelihood)គឺការចិញ្ចឹមជីវិតត្រឹមត្រូវ វៀរចាកការធ្វើជំនួញខុស៥យ៉ាង គឺជួញដូរមនុស្ស ជួយដូរអាវុធយុទ្ធភណ្ឌ ជួញដូរគ្រឿងញៀន ថ្នាំពេទ្យក្លែងក្លាយ ថ្នាំពិស ជួញដូរសាច់រស់ និងជួញដូរគ្រឿងស្រវឹង។ ចំណែកមេដឹកនាំវិញជាបុគ្គលដែលមានឱកាសច្រើនក្នុងការស្វែងរកភាពមានបានដល់ខ្លួន ប្រាក់ខែរបស់រដ្ឋព្រមទាំងគ្រឿងអំនួយភាពសុខសប្បាយផ្សេងៗក៏មានការឧបត្ថម្ភពីថវិកាជាតិផងដែរ ដូច្នេះមេដឹកនាំគួរតែមានសម្មាអាជីវៈ តាមភាពមានបានដែលរដ្ឋផ្តល់ឲ្យ មិនគួរមានចិត្តលោភលន់ពុករលួយយកថវិកាជាតិរបស់សួនរួមមកកសាងភាពមានបានសំរាប់គ្រួសារខ្លួននិងបក្សពួកខ្លួនឡើយ។ ការ

មានឱកាសជាមេដឹកនាំគឺវាគ្រប់គ្រាន់ទៅហើយក្នុងការបន្សល់ទុកកិត្តិនាមនិងគំរូល្អៗដល់ហ្វូងជនទាំងពួង ។

២.**សមាធិ**(Samadhi or meditation, concentration, oneness of the mind)គឺការបង្វឹកចិត្តឲ្យមានភាពចុះផ្លុងទៅក្នុងអារម្មណ៍មិនរើរវាយ ការធ្វើចិត្តឲ្យជាឯកតារម្មណ៍ ធ្វើចិត្តឲ្យស្ងប់រំងាប់ ដើម្បីជាកំពែងការពារនូវអកុសលធម៌ទាំងពួង។ ខ្មែរយើងច្រើនយល់ខុសថា សមាធិជាការធ្វើឲ្យមនុស្សយើងមិនចង់ធ្វើការងារ ធ្វើឲ្យមនុស្សយើងមានការធុញទ្រាន់នឹងជីវិតក្រុមគ្រួសារសាច់ញាតិ ហើយសមាធិនេះអាចធ្វើឲ្យមនុស្សឆ្កួតជាដើម។ ទាំងអស់នេះជាការយល់ខុសធំណាស់សម្រាប់អ្នកដែលមិនធ្លាប់បានធ្វើសមាធិ។ តាមពិតសមាធិធ្វើឲ្យយើងមានកំឡាំងកាយ កំឡាំងចិត្ត និងកំឡាំងបញ្ញា កាន់តែខ្លាំងឡើងក្នុងការបំពេញតួនាទីកិច្ចការងារទាំងពួង។ សមាធិប្រដាប់ដោយអង្គប្រកបបីយ៉ាងគឺ :

- សម្មាវិរិយៈ(right effort) គឺការព្យាយាមត្រូវ មានដូចជាព្យាយាមមិនធ្វើនូវអំពើបាបទាំងពួង លះបង់នូវអំពើបាបទាំងពួងដែលមាននៅក្នុងខ្លួន ប្រឹងប្រែងធ្វើនូវអំពើជាកុសលនិងប្រឹងប្រែងការពារនូវអំពើកុសលដែលមានហើយឲ្យស្ថិតនៅជាអមតៈ ។
- សម្មាសមាធិ(right meditation) គឺការតំកល់ចិត្តត្រូវ ការប្តេជ្ញាចិត្តត្រូវ ការពលិកម្មត្រូវ និងការតាំងសច្ចាប្រណិធានត្រូវ ។
- សម្មាសតិ(right mindfulness) គឺការមានសតិសម្បជញ្ញៈត្រូវ ដែលសតិសម្ប -ជញ្ញៈនេះជាធម៌ ដែលមានឧបការគុណច្រើនជាងគេ។

៣.**បញ្ញា**(Panna or wisdom) គឺកត្តាដែលអាចធ្វើឲ្យយើងសម្រេចកិច្ចការទាំងពួង។ បញ្ញាក្នុងព្រះពុទ្ធសាសនាមានពីរយ៉ាងគឺលោកីយបញ្ញានិងលោកុត្តរបញ្ញា។ លោកីយបញ្ញាសំដៅទៅលើការចេះដឹងឈ្លាសវាងវៃនូវរឿងដំណោះស្រាយខាងផ្លូវលោកដូចជាបញ្ហានយោបាយសេដ្ឋកិច្ច សង្គមកិច្ច ចរិយធម៌ សង្គម នីតិវិធី និងចិត្តសាស្ត្រជាដើម។ លោកុត្តរធម៌សំដៅយកការចេះដឹងយល់ច្បាស់នូវសច្ចភាពពិតនៃជីវិត ដូចជាយល់ថាជីវិតគឺអនិច្ចំមិនទៀងទាត់

ជីវិតគឺទុក្ខំជាវត្ថុធាតុដែលត្រូវប្រែះធ្លាយជាធម្មតា និងជីវិតគឺអនត្តាមិនមែនជារបស់ខ្លួនឡើយ ពីព្រោះយើងមិនអាចបង្គាប់បញ្ជាវាកុំឲ្យចាស់ឈឺស្លាប់បាន។ ពេលណាយើងយល់នូវត្រៃលក្ខណៈនៃធម្មជាតិនេះហើយធ្វើឲ្យយើងជាមេដឹកនាំដែលអាចប្តេជ្ញាចិត្តឧទ្ទិសខ្លួនជាអ្នកជួយសង្គម និងអ្នកដទៃដោយពុំគិតពីប្រយោជន៍ផ្ទាល់ខ្លួនឡើយ។ ម្យ៉ាងវិញទៀតការមានលោកុត្តរបញ្ញានៅក្នុងចិត្តនេះ ធ្វើឲ្យយើងម្នាក់ៗជាពិសេសមេដឹកនាំមានហិរិគឺខ្មាសបាប និងមានឱត្តប្បៈ គឺការខ្លាចបាបនៅក្នុងខ្លួន។

សីល សមាធិ បញ្ញា នេះចាត់ទុកថាជាមេរៀនកំរិតខ្ពស់មួយសំរាប់បុគ្គលដែលយល់និងមានសម្មាទិដ្ឋិរឹងមាំ។ សំរាប់បុគ្គលដែលទើបតែចាប់ផ្តើមរៀនសូត្រមេរៀនទាំងបីនេះគួរតែចាប់ផ្តើមមេរៀនទីមួយដោយការធ្វើទាន មេរៀនទីពីរគឺការរក្សាសីល និងមេរៀនទីបីគឺការចំរើនភាវនា ។

១. **ទាន**(Dana or generosity)មានន័យថាការឲ្យ ការជួយសង្គ្រោះគ្នាទៅវិញទៅមក ការមានសន្តានចិត្តចេញមកអំពីការលះបង់ពិតប្រាកដ។ ទាននេះបែងចេញជាបីគឺ -អាមិសទានជាទានដែលប្រកបដោយវត្ថុមានបច្ច័យ៤ជាដើម, -ធម្មទាន ជាទានដែលជួយគ្នាដោយពាក្យទូន្មានល្អ។ និង -អភ័យទាន ជាទានដែលផ្តល់ឲ្យគ្នាទៅវិញទៅមកដោយការអភ័យទោសកំហុសឆ្គងទាំងពួង។ ជាពិសេសចំពោះការធ្វើទាន មេដឹកនាំត្រូវតែសិក្សាឲ្យល្អិតចំពោះការបដិបត្តិមេរៀនទី១នេះ។ ទានដែលត្រឹមត្រូវ ត្រូវមានអង្គប្រកបគ្រប់គ្រាន់របស់វាបីយ៉ាងមានវត្ថុទាន អ្នកឲ្យទាន និងអ្នកទទួលទានជាដើម។ នៅក្នុងសង្គមប្រជាធិបតេយ្យប្រទេសដែលមានការគោរពច្បាប់ពិតប្រាកដ មានប្រព័ន្ធយុត្តិធម៌ស្មើភាគគ្នាសំរាប់ប្រជាជនទូទៅ ការធ្វើទានចែកអំណោយរបស់មេដឹកនាំនិងមន្ត្រីរាជការចំពោះប្រជាជនទូទៅដែលជាអ្នកបោះឆ្នោតឲ្យខ្លួនជាការខុសច្បាប់និងមិនសមរម្យមួយ។ តែអ្វីដែលមេដឹកនាំអាចជួយវិភាគទានឬការធ្វើទានឲ្យបានត្រឹមត្រូវតាមព្រះពុទ្ធសាសនានោះ គឺត្រូវជួយប្រជាជនរស់នៅឲ្យបានស្មើភាគគ្នាក្នុងការមានបច្ច័យ៤ប្រើប្រាស់ ការសិក្សារៀនសូត្រ ការចូលរួមក្នុងសង្គម

មានការបញ្ចេញមតិជាដើម និងការមានការងារធ្វើសមរម្យទៅតាមកំឡាំងសមត្ថភាព និងកិរិតវិជ្ជារបស់ខ្លួន ដែលនេះជាទានមួយសំខាន់ណាស់សំរាប់មេដឹកនាំទាំងឡាយ ។

២. ***សីល*** គឺការសង្រួមកាយនិងវាចារបស់ខ្លួនឲ្យស្ថិតក្នុងសតិសម្បជញ្ញៈជានិច្ច។ មេដឹកនាំត្រូវវៀរចាកការសំឡាប់ បៀតបៀន ធ្វើទុកបុកម្នេញអ្នកដទៃ ដោយប្រកាន់យកមេត្តាធម៌ជាធំ។ វៀរចាកការប្រព្រឹត្តអំពើពុករលួយ កេងប្រវ័ញ្ចញើសឈាមប្រជាពលរដ្ឋ ប្រកបតែអំពើសុចរិតជាគំរូគេក្នុងការលះបង់និងការមិនឃើញប្រយោជន៍ផ្ទាល់ខ្លួន។ វៀរចាកការប្រព្រឹត្តខុសច្បងមានការក្បត់ចិត្តគូស្វាមីភរិយា និងការមានប្រពន្ធចុងឬស្រ្តីលួចលាក់ច្រើន គួរតែមានការធ្វើតបៈសង្រួមនៅក្នុងរឿងកាមគុណ។ ចំណែកវាចាវិញ មេដឹកនាំត្រូវតែមិននិយាយកុហក់ មិននិយាយក្រឡិចក្រឡុច មិននិយាយញុះញង់ មិននិយាយពាក្យអសុរសអាសអាភាសជេរប្រទេចបណ្តាសា និងមិននិយាយពាក្យរោយរាយឥតប្រយោជន៍ ដោយនិយាយតែពាក្យពិត ពាក្យដែលនាំឲ្យប្រជាជនមានភាពទុកចិត្ត កក់ក្តៅចិត្ត ពាក្យដែលជាសុភាសិត និងនិយាយពាក្យដែលមានប្រយោជន៍តាមទស្សនវិស័យវិញ្ញូជន ។

៣. ***ភាវនា*** មានន័យថាការអភិវឌ្ឍន៍ ដែលមេដឹកនាំត្រូវតែជួយអភិវឌ្ឍន៍សង្គមជាតិ និងប្រជារាស្រ្តឲ្យមានការរីកចំរើនទន្ទឹមគ្នាដូចជាការអភិវឌ្ឍន៍ផ្លូវកាយឬសេដ្ឋកិច្ច ការអភិវឌ្ឍន៍ផ្លូវចិត្តឬទំនួលខុសត្រូវប្រកបដោយហិរិនិងឱត្តប្បៈ ការអភិវឌ្ឍន៍ផ្លូវសីលឬក្រិតក្រមសីលធម៌ និងការអភិវឌ្ឍន៍ផ្លូវធម៌ឬភាពត្រឹមត្រូវមានការគោរពច្បាប់ជាធំ។ ការអភិវឌ្ឍន៍សំខាន់ដែលត្រូវចាប់ផ្តើមមុនគេ គឺការអភិវឌ្ឍន៍ខ្លួនឯង មានដូចជាកាយភាវនា ការអភិវឌ្ឍន៍ផ្លូវកាយ, ចិត្តភាវនា ការអភិវឌ្ឍន៍ផ្លូវចិត្ត, សីលភាវនា ការអភិវឌ្ឍន៍ផ្លូវសីលធម៌ និងបញ្ញាភាវនា ការអភិវឌ្ឍន៍ផ្លូវសតិបញ្ញា។ ពេលយល់ឃើញថា ខ្លួនឯងមានការអភិវឌ្ឍន៍ត្រឹមត្រូវហើយ គួរតែចេញទៅជួយអភិវឌ្ឍន៍អ្នកដទៃតាមរយៈការប្រព្រឹត្តបដិបត្តិនិងការឈានមុខគេនូវគ្រប់វិស័យ។

## ផ្លូវកណ្ដាលជាផ្លូវតែមួយគត់សំរាប់មេដឹកនាំ

ផ្លូវកណ្ដាលឬមជ្ឈិមាបដិបទា ជាផ្លូវតែមួយគត់ដែលព្រះពុទ្ធអង្គទ្រង់បានត្រាស់ដឹង ហើយអប់រំណែនាំឲ្យយើងទាំងឡាយបដិបត្តិតាមវិធីនេះដើម្បីឲ្យជីវិតបានជោគជ័យជួបប្រទះតែសេចក្ដីសុខ សេចក្ដីចំរើន និងបានសំរេចនូវបរមសុខគឺព្រះនិព្វាន។ ផ្លូវកណ្ដាលរបស់ព្រះពុទ្ធគឺខុសពីផ្លូវកណ្ដាលរបស់ប្លាតុងឬអ្វីដែលយើងធ្លាប់គិតថាវានៅចំកណ្ដាលរវាងចុងទាំងពីរនៃខ្សែត្រង់ ឬអ្វីដែលយើងតែងគិតថារវាងល្អនិងអាក្រក់។ តែសេចក្ដីពិត ផ្លូវកណ្ដាលរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ជាផ្លូវកណ្ដាលបែបរង្វង់មូល។ ការបដិបត្តិឲ្យបានត្រឹមត្រូវ គឺបដិបត្តិដូចអ្នកបាញ់ព្រួញ បាញ់ទៅរកចំណុចកណ្ដាលនៅក្នុងរង្វង់មូលដូច្នោះឯង ។

ផ្លូវកណ្ដាល(មជ្ឈិមាបដិបទា)នេះ គឺការវៀរចាកវិធីជ្រុលនិយមពីរយ៉ាង ការជ្រុលនិយមទៅខាងវត្ថុឬការសេពកាមគុណ សប្បាយភ្លើតភ្លើន(កាមសុខល្លិកានុយោគ) និងការជ្រុលនិយមទៅខាងការប្រព្រឹត្តតឹងតែង ជាតិនិយមចាស់គំរិលហួសហេតុ(អត្តកិលាមថានុយោគ)។ ការមិនបដិបត្តិជ្រុលនិយមនេះ ជាការធ្វើឲ្យមានតុល្យភាពផងដែរនូវការអភិវឌ្ឍន៍សម្ភារៈខាងសេដ្ឋកិច្ចត្រូវដើរទន្ទឹមគ្នានឹងការអភិវឌ្ឍន៍គុណតំលៃខាងសីលធម៌។ ដូចគ្នាដែរ មេដឹកនាំត្រូវតែបដិបត្តិឲ្យមានតុល្យភាពរវាងការធ្វើឲ្យគេស្រលាញ់(បិយៈ)និងការគោរព(គរុ), ការមានព្រះតេជ(អំណាច)និងព្រះគុណ(គុណធម៌) និងការមានវិជ្ជាប្រកបដោយគុណធម៌ជាដើម។

ការបដិបត្តិតាមផ្លូវកណ្ដាលនេះជាការលើកស្ទួយឲ្យយើងយល់នូវហេតុផល(អរិយសច្ចៈ៤) ការយល់នូវជំរៅនៃមគ្គវិធីនាំទៅរកការរីកចំរើន(អរិយមគ្គប្រកបដោយអង្គ៨) និងការយល់នូវហេតុបច្ច័យការជំពាក់ទាក់ទិនគ្នា អាស្រ័យគ្នាទៅវិញទៅមក មិនអាចកាត់ផ្ដាច់ពីគ្នាបានឡើយនូវគ្រប់បញ្ហាទាំងអស់(បដិច្ចសមុប្បាទៈ) ។

ប្រទេសប្រជាធិបតេយ្យដែលមានការអភិវឌ្ឍន៍ជាច្រើន បានកំពុងព្យាយាមអភិវឌ្ឍជាតិរបស់គេឲ្យមានតុល្យភាពរវាងធនធានធម្មជាតិនិងការចំរាញ់ផលខាងសេដ្ឋកិច្ច, ការ

បង្កើនចំនួនបញ្ញាវ័ន្តនិងទីផ្សារការងារ, កំណើនប្រជាជននិងកំណើនសេដ្ឋកិច្ច, ការអភិវឌ្ឍន៍ផ្លូវលោកនិងផ្លូវធម៌, ហើយជាពិសេសគឺការគាំទ្រឲ្យប្រជាជននៅក្នុងសង្គមមានសិទ្ធិក្នុងការរស់នៅស្មើភាពគ្នា មានបច្ច័យបួនប្រើប្រាស់ស្មើគ្នា ដោយការធ្វើនយោបាយសេដ្ឋកិច្ចដាក់កំហិតដល់បុគ្គលដែលមានធនធានច្រើន ឬមានប្រាក់បៀវត្សរ៍ច្រើន ត្រូវបង់ពន្ធដារចូលរដ្ឋច្រើនដែរ ដើម្បីបង្វែរលុយទាំងនោះមកចែកចាយដល់បុគ្គលទន់ខ្សោយ និងអ្នកដែលមានចំណូលក្នុងគ្រួសារទាបក្រោមកំរិតនៃជីវភាពចាំបាច់របស់ជីវិត ។

## មេដឹកនាំល្អត្រូវភ្ញាក់រលឹកជាប់ជានិច្ច

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គជាអ្នកភ្ញាក់ពីដំណេកត្រាំនៅក្នុងកងកិលេសមានលោភៈ ទោសៈ មោហៈ និងអវិជ្ជាជាដើម ទើបព្រះអង្គបានក្លាយទៅជាមេដឹកនាំគំរូគេជាសាស្តានៃទេវតានិងមនុស្សទាំងពួង។ សតិនិងសម្បជញ្ញៈជាធម៌ដែលមានឧបការគុណច្រើនជាងគេក្នុងការធ្វើឲ្យមេដឹកនាំភ្ញាក់រលឹកជាប់ជានិច្ច ប្រកបដោយសមាធិចិត្តក្នុងការបំពេញតួនាទី គូសវាសគំនិតថ្មីៗ និងការដោះស្រាយបញ្ហាទាំងឡាយ។ ការបដិបត្តិដែលអំណោយផលច្រើនដល់ការរក្សាសតិគឺការចំរើននូវសមថកម្មដ្ឋានឬវិបស្សនាកម្មដ្ឋាន ឬសរុបដោយខ្លីគឺការមានសតិជាប់ជានិច្ច(សតិមា)និងការដឹងខ្លួនជានិច្ច(សម្បជានោ) នូវរាល់សកម្មភាពទាំងអស់របស់រាងកាយ ។

នៅក្នុងរាងកាយរបស់យើង មានវត្ថុសំខាន់បីយ៉ាង ដែលយើងអាចហៅថាត្រីមុខ ឬអ្នកនាំមុខគេបីយ៉ាងគឺ គំនិត សំដី និងសកម្មភាព។ គំនិតមានប្រភពចេញពីចិត្ត ដែលជាផ្នែកមួយសំខាន់ជាងគេបំផុត។ មនុស្សយើងមិនអាចមានពាក្យសំដីឬសកម្មភាពអ្វីបានឡើយប្រសិនបើយើងគ្មានការគិតព្រាងទុកជាមុន។ ដូច្នេះហើយ បានជាមេដឹកនាំល្អ ត្រូវតែស្ទាត់ជំនាញក្នុងការបញ្ជាចិត្តខ្លួនឯងឲ្យគិតនៅក្នុងផ្លូវគំនិតដែលត្រឹមត្រូវ ច្បាស់លាស់និងប្រកបដោយហេតុផល។ មនុស្សយើងមានចិត្តជាប្រធាន មានចិត្តធំ មានចិត្តជាតួនាំ អ្វីគ្រប់យ៉ាង

កសាងឡើងអំពីចិត្ត ដូច្នេះបើចង់ធ្វើជាមេដឹកនាំល្អ ហើយអាចគ្រប់គ្រងអ្នកដទៃបាននោះ ត្រូវហ្វឹកអប់រំ ដឹកនាំនិងគ្រប់គ្រងចិត្តរបស់ខ្លួនឯងសិន។ ការតំកល់ចិត្តឲ្យភ្ញាក់រលឹកជាប់ជានិច្ចប្រកបដោយសតិសម្បជញ្ញៈ ជាផ្នែកមួយសំខាន់នៃការដឹកនាំនិងគ្រប់គ្រងចិត្តរបស់ខ្លួន ។

តាមសេចក្តីពិត មនុស្សយើងអាចអប់រំពាក្យសំដីនិងសកម្មភាពរបស់ខ្លួនបានតាមរយៈការមានសីលឬវិន័យឬក្រិតក្រមច្បាប់នៅក្នុងខ្លួននិងច្បាប់សង្គម តែវាមិនអាចអប់រំផ្នែកផ្នត់គំនិតបានឡើយ។ មានតែសមាធិប៉ុណ្ណោះដែលអាចអប់រំទៅលើផ្នត់គំនិតរបស់មនុស្សបាន ហើយសមាធិនេះឯងជាឧបករណ៍សំខាន់សំរាប់ធ្វើឲ្យអ្នកក្លាយជាមេដឹកនាំដ៏ពូកែប្រកបដោយគុណធម៌ ឬធ្វើឲ្យមនុស្សបុថុជ្ជនក្លាយទៅជាអរិយជនបាន ។

## គុណសម្បត្តិវិជ្ជាតក្នុងរឿងសេដ្ឋកិច្ច

រឿងក្រពះរបស់ប្រជារាស្ត្រ ជារឿងចាំបាច់បំផុតមួយសំរាប់មេដឹកនាំទាំងឡាយក្នុងលោកយើងនេះ។ ពេលណាប្រជាជនមានហូបចុកគ្រប់គ្រាន់ សន្តិភាពសង្គមក៏មានល្អ សីលធម៌ការរស់នៅនិងវិស័យការគោរពច្បាប់ក៏មានល្អផងដែរ។ តែពេលណាសេដ្ឋកិច្ចខ្សត់ខ្សោយ ប្រជាជនស្ថិតក្រោមបន្ទាត់នៃភាពក្រីក្រគឺមានបច្ច័យបួនប្រើប្រាស់មិនគ្រប់គ្រាន់ សង្គមនោះនិងសំបូរទៅដោយអាជ្ញាកម្ម ចំបាំងរាំងជល់ បំពានគ្នាទៅវិញទៅមក មានការរើសអើង ការប្រកាន់វណ្ណៈ អំពើពុករលួយ និងវិទ្ធង្សនាផ្សេងៗ ។

នៅក្នុងក្រុងសាវត្ថីកាលពីសម័យពុទ្ធកាលក៏ធ្លាប់មានបញ្ហាសេដ្ឋកិច្ចនិងសង្គមធ្លាក់ចុះដែរ ហើយព្រះពុទ្ធអង្គបានទេសនាប្រៀនប្រដៅដល់មេដឹកនាំនគរនោះ នូវមូលហេតុពិតនៃទុក្ខសោកសង្គមនោះថាបណ្តាលមកពី

- សេចក្តីស្រើងក្នុងកាមតណ្ហា
- សេចក្តីល្មោភលោភលន់គ្មានចប់

- មិនត្រឹមតែមិនប្រកាន់យកសីលធម៌ជាគូជីវិតប៉ុណ្ណោះទេ ថែមទាំងប្រកាន់យកជំនឿអរូបីយ៍ មានមន្តអាគមន៍គាថា ស្តោះផ្លុំ កាត់គ្រោះហ៍ ទោះទាយ ជាដើម ជាធំថែមទៀត ។
- វណ្ណៈខ្ពស់ជិះជាន់មើលងាយមើលថោកវណ្ណៈទាប មន្ត្រីរាជការជិះជាន់រាស្ត្រក្រខ្សត់ ។
- តុលាការមិនមានតម្លាភាពនិងយុត្តិធម៌សំរាប់ប្រជាពលរដ្ឋ
- គ្មានសេចក្តីគោរព គ្មានសេចក្តីគួរសមរវាងគ្នានិងគ្នា ឃើញខុសថាជាត្រូវ ឃើញសថាជាខ្មៅ ឃើញអាក្រក់ថាជាល្អ ។
- អ្នកមានអំណាចមានសេចក្តីព្រហើនកោងកាច ប្រាសចាកសេចក្តីមេត្តាករុណា ប្រកាន់អំណាចជាធម៌ មិនមែនប្រកាន់ធម៌ជាអំណាច ។
- អ្នករដ្ឋការមិនមែនត្រឹមតែមិនបំពេញករណីកិច្ចដើម្បីសេចក្តីសុខសាន្តរបស់រាស្ត្រ ឬគោរពកោតខ្លាចរាស្ត្រទេ តែប្រើអំណាចសំឡុតគំរាមកំហែងប្រជារាស្ត្រ ។

ក្នុងការអភិវឌ្ឍន៏ជាតិគួរដោះស្រាយឲ្យប្រជាជនបានទទួលនូវសេចក្តីសុខពីរយ៉ាងគឺសុខផ្លូវកាយ និង សុខផ្លូវចិត្ត។ សុខផ្លូវកាយមានដូចជា

- ប្រជាជនមានបច្ច័យបួនប្រើប្រាស់គ្រប់គ្រាន់។ បច្ច័យទាំងបួននោះគឺសំលៀកបំពាក់គ្រប់ដណ្តប់រាងកាយ ម្ហូបអាហារចំណីផ្លែឈើមានជីវជាតិ ផ្ទះសំបែងស្អាត ផ្លូវថ្នល់និងយានពាហនះ និងមន្ទីរពេទ្យ គ្រូពេទ្យ ថ្នាំពេទ្យ មណ្ឌលសុខភាព មណ្ឌលអនាម័យគ្រប់គ្រាន់ ។
- មានបរិដ្ឋានល្អដោយការអភិវឌ្ឍន៏សួនច្បារសាធារណៈជាទីលំហែកាយឲ្យបានច្រើនរក្សាមណ្ឌលអនុរក្សតំបន់ភ្នំ និងព្រៃឈើពិសេស ដើម្បីបានជាតំបន់ទេសចរណ៏ធម្មជាតិសំរាប់ភ្ញៀវជាតិនិងអន្តរជាតិ ។

- ប្រជាជនមិនទទួលការវាយតប់ទាត់ធាក់ពីសំណាក់ជនណាមួយឬអាជ្ញាធររដ្ឋ ព្រោះហេតុការណ៍ខុសឆ្គងឬបំពានអ្វីមួយ។ ហេតុការណ៍គ្រប់យ៉ាងត្រូវប្រព្រឹត្តទៅតាមផ្លូវច្បាប់តុលាការដ៏សមធម៌មួយ ។
- ផ្តល់បៀវត្សរ៍គ្រប់គ្រាន់ដល់មន្ត្រីរាជការអ្នកបំរើជាតិ ជាពិសេសគ្រូបង្រៀន ទៅតាមសមត្ថភាពរៀងៗខ្លួន។ ជួយរកទីផ្សារការងារឲ្យប្រជាជនមានការងារធ្វើទាំងនិស្សិតបញ្ញវន្ត និងកសិករជនបទ ឲ្យបានទទួលថ្លៃឈ្នួលសមរម្យសំរាប់ជីវភាពប្រចាំថ្ងៃ។ ការជួយនេះ មិនមែនជួយដោយការយកអំណោយនេះ អំណោយនោះទៅដើរចែកប្រជាជននោះទេ ព្រោះមិនមែនជាការផ្តល់សេចក្តីសុខផ្លូវកាយដល់ប្រជាពលរដ្ឋយូរអង្វែង និងសមស្របតាមនីតិកម្មឡើយ ។

ចំណែកសេចក្តីសុខផ្លូវចិត្តមានដូចជា

- លើកស្ទួយការប្រព្រឹត្តបដិបត្តិខាងផ្លូវសាសនាដែលបង្រៀនធម៌ពិតជៀសវាងជំនឿអរូបីយ៍ ដែលជាផ្នែកមួយពង្រឹងក្របសីលធម៌ និងជាទីពឹងពំនាក់ខាងផ្លូវចិត្ត។ ដោយប្រជាជនខ្មែរភាគច្រើនលើសលុបជាពុទ្ធសាសនិកជន ស្ថាប័នព្រះពុទ្ធសាសនា គួរតែត្រូវបានពង្រឹងតាំងតែថ្នាក់លើរហូតដល់ថ្នាក់ក្រោម ការបួសរបស់កុលបុត្រខ្មែរគួរពង្រឹងក្នុងក្របធម៌វិន័យច្បាស់លាស់ ទំនុកបំរុងសាលារៀនពុទ្ធិកសិក្សានិងសកលវិទ្យាល័យព្រះពុទ្ធសាសនា ដើម្បីឲ្យសមណសិស្សបានរៀនសូត្រពង្រីកចំណេះដឹងឲ្យបានខ្ពង់ខ្ពស់មុននឹងយកទៅអប់រំដល់អ្នកដទៃ។ ជាពិសេសមជ្ឈមណ្ឌលវិបស្សនានិងការបដិបត្តិសមាធិ គួរតែត្រូវបានពង្រឹងនិងពង្រីកដោយថ្នាក់ដឹកនាំរដ្ឋ ។ មេដឹកនាំរដ្ឋ មន្ត្រីរាជការស៊ីវិល កងយោធពល នគរបាល និងសិស្សនិស្សិត គួរមានគំរោងការចូលរួមហ្វឹកហ្វឺនផ្លូវចិត្តដោយការបដិបត្តិសមាធិវិបស្សនា ឲ្យបានយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ។

- ផលិតផលធានមនុស្សឲ្យបានច្រើននិងមានប្រសិទ្ធិភាពខ្ពស់ ដើម្បីឲ្យបុគ្គលម្នាក់ៗនោះមានទីពឹងខ្លួនឯងដោយមានចំណេះពិតប្រាកដនៅក្នុងខ្លួន។ រៀបចំប្រព័ន្ធអប់រំរយៈពេលវែងសំរាប់ជនទូទៅនិងគ្រប់វ័យទាំងអស់ ។
- មិនធ្វើនយោបាយបោកបញ្ឆោត និងវិទ្ធង្សនាបំភាន់ប្រជាជនក្នុងការពង្រឹងអំណាចខ្លួនឯងឡើយ។ កិច្ចការគ្រប់យ៉ាងត្រូវតែប្រព្រឹត្តទៅតាមតម្លាភាព វិមជ្ឈការ និងនីតិកម្ម ដើម្បីឲ្យប្រជាជនមានភាពកក់ក្តៅក្នុងចិត្តថាអ្វីគ្រប់យ៉ាងត្រូវបានដោះស្រាយទៅតាមគន្លងច្បាប់របស់រដ្ឋ ប្រកបដោយអព្យាក្រិតភាព។

នៅក្នុងគម្ពីរសំយុត្តិកនិយាយ សគាថវគ្គ ព្រះពុទ្ធអង្គទ្រង់សំដែងប្រាប់ដល់ព្រាហ្មណ៍ពីការបូជាយញ្ញ៥យ៉ាងដូចជាការសំឡាប់សេះ សំឡាប់មនុស្ស ការដាក់អន្ទាក់ ការផឹកថ្នាំកំឡាំង និងការបូជាទូទៅ[១] ឲ្យផ្លាស់ទៅជាការបដិបត្តិនូវរាជសង្គហវត្ថុ៤[២] ឬការសង្គ្រោះបួនយ៉ាងរបស់មេដឹកនាំដល់ប្រជាពលរដ្ឋគឺ

១. មានការឆ្លាតពូកែក្នុងការធ្វើឲ្យសេដ្ឋកិច្ចដើរ ផ្តល់ពូជ ដី ប្រព័ន្ធធារាសាស្រ្ត ផលិតផលកសិកម្មនិងឧស្សាហកម្មមានបរិបូរណ៍គ្រប់គ្រាន់សំរាប់ប្រើប្រាស់ ក្នុងស្រុក និងអាចនាំចេញក្រៅស្រុកថែមទៀត ។

២. ឆ្លាតវាងវៃក្នុងការដោះស្រាយបញ្ហារដ្ឋបាលសាធារណៈ មានការរើសមនុស្សល្អឲ្យចូលមកធ្វើការផ្តល់រង្វាន់ដល់អ្នកដែលមានស្នាដៃចំពោះជាតិមាតុភូមិ និងពូកែក្នុងការចាត់ចែងការងារសមរម្យទៅតាមសមត្ថភាពមនុស្ស ។

៣. ឆ្លាតវាងវៃក្នុងការដោះស្រាយបញ្ហាសង្គម លើកស្ទួយកិរិតការសិក្សា អប់រំទាំងការអប់រំរយៈវែងនិងរយៈខ្លី លើកកំពស់មនុស្សល្អនិងដាក់ទោសជនប្រព្រឹត្តល្មើសនឹងច្បាប់សង្គម រកទីផ្សារការងារផ្តល់ជូនដល់ប្រជាពលរដ្ឋទៅតាមលទ្ធភាព សមត្ថ

---

*១. អស្សមេធៈ, បុរិសមេធៈ, សម្មាមេធៈ, វាជបេយៈ និង និរគ្គឡៈ ឬ សព្វមេធៈ*

*២. សស្សមេធៈ, បុរិសមេធៈ, សម្មាបាសៈ និង វាជបេយៈ*

*ភាពនិងទេពកោសល្យតែរៀងៗខ្លួន។ ជាពិសេសអ្នកដែលមកកាន់កាប់ការងាររដ្ឋត្រូវតែមានទាំងចំណេះដឹង ចំណេះធ្វើ គុណធម៌ការលះបង់ ភាពបរិសុទ្ធិចិត្ត និងសីលធម៌ខ្ពស់ ។*

*៤. មានវាចាពីរោះពិសារ វាចាដែលសច្ចៈទៀងត្រង់ វាចាដែលនាំមកនូវ សាមគ្គីធម៌ វាចាដែលនាំប្រយោជន៏មកឲ្យនិងផ្តល់កំឡាំងដល់អ្នកធ្វើល្អ ។*

### *គោលការណ៍១២យ៉ាងរបស់អ្នកដឹកនាំដែលជាស្តេចចក្រពត្តិ*[៣]

*ចក្រពត្តិ តាមភាសាបាលីប្រែថា ស្តេចឬក៏អ្នកដឹកនាំដែលមានអំណាចឫទ្ធានុភាពដ៏ខ្លាំងក្លា ឬជាអ្នកមានបុណ្យបារមីខ្លាំង ព្រោះបានមកអំពីការបដិបត្តិតាមគោលបារមីធម៌១២យ៉ាងគឺ*

*១. គោរពរាប់អានធម៌ជាធំ បូជាកោតក្រែងធម៌ យកធម៌ជាគោល យកធម៌ជាត្រីវិស័យ និងយកធម៌ជាទង់ជ័យ ។*

*២.ចាត់រក្សាការពារនិងគ្រប់គ្រងដោយត្រឹមត្រូវតាមធម៌ និងជាធម៌ ដល់ជនខាងក្នុងតាំងតែភរិយា បុត្រាបុត្រី រហូតដល់មន្ត្រីរាជការស្ថិតក្រោមបង្គាប់បញ្ជា ឲ្យមានរបៀបរៀបរយ មានសណ្តាប់ធ្នាប់ និងគោរពរាប់អានស្មោះស្ម័គ្រនឹងគ្នា។*

*៣.ពិនិត្យដិតដល់ ដល់កងកំឡាំងរាជអាវុធហត្ថ ដែលឈរជើងការពារតាមតំបន់ព្រំដែន និងទីតាំងដាក់ពង្រាយទាំងឡាយ ឲ្យបានទទួលការផ្គត់ផ្គង់ទាំងផ្នែកសម្ភារៈនិងស្មារតី។*

*៤.មើលទំនុកបំរុងដល់ប្រទេសដែលជាចំណុះទាំងឡាយ ឬជនជាតិភាគតិចដែលមានវិធីជីវិតប្រពៃណីទំនៀមទំលាប់ខុសពីយើង ឲ្យរស់នៅបានសុខស្រួល មានការអភិវឌ្ឍន៏ស្មើភាគគ្នា និងបានទទួលសិទ្ធិសេរីភាពគ្រប់គ្រាន់ទៅតាមច្បាប់ ។*

---

*៣. ធម្មាធិបតេយ្យ, អន្តោជន, ពលកាយ, ខត្តិយ, អនុយន្ត, ព្រាហ្មណគហបតី, នេគមជានបទ, សមណព្រាហ្មណ៏, មិគបក្សី, មាអធម្មការ, ធនានុប្រទាន, សមណព្រាហ្មណបរិបុច្ឆា*

៥.មើលការខុសត្រូវ ទំនុកបំរុងឲ្យបានគ្រប់គ្រាន់ដល់រាជបរិពារ មន្ត្រីរាជការស៊ីវិលទាំងអស់ដោយផ្គត់ផ្គង់ប្រាក់ខែ ប្រាក់បំណាច់ឲ្យបានសមរម្យទៅតាមតំរូវការជីវិតជាដើម ។

៦.ចាត់រក្សាការពារនិងគ្រប់គ្រងយ៉ាងត្រឹមត្រូវដល់បណ្ឌិតបញ្ញវន្ត អ្នកជំនួញ ម្ចាស់ដី អ្នកប្រកបអាជីវកម្មខ្នាតតូចឬខ្នាតធំ គ្រូបង្រៀន និយោជិក និយោជក កម្មករ ព្រមទាំងឧបករណ៍ប្រើប្រាស់ទាន់សម័យជាដើម ។

៧.គ្រប់គ្រងរក្សាការពារយ៉ាងស្មើភាគគ្នាដល់ពួងជនទាំងឡាយដែលស្ថិតនៅក្រោមការដឹកនាំ ទោះរស់នៅនិគមជនបទ ទីក្រុង ឬតំបន់ដាច់ស្រយាលជាយដែនក៏ដោយ។

៨.ឧបត្ថម្ភគាំពារដល់ព្រះសង្ឃនិងបព្វជិតដែលដើរតួជាអ្នកគំរូគេក្នុងការអនុវត្តគុណធម៌ និងការប្រកាន់ខ្ជាប់ក្នុងធម៌វិន័យដែលជានិមិត្តសញ្ញានៃអំពើល្អទាំងពួង ។

៩.យកចិត្តទុកដាក់រក្សាតំបន់អនុរក្សសត្វព្រៃ ព្រៃឈើ និងឧទ្យានជាតិពិសេសឲ្យបានច្រើននិងមានប្រសិទ្ធិភាព ។

១០.បង្ក្រាបមិនឲ្យមានឧក្រិដ្ឋកម្ម ចោរកម្ម អំពើអាក្រក់ឃោរឃៅទាំងឡាយកើតមានក្នុងប្រទេស ។

១១.បែងចែកទ្រព្យសម្បត្តិជាតិដែលរកបានមកដោយសម្បត្តិជាតិនិងពន្ធដាររបស់ប្រជាជន ឲ្យបានសមរម្យត្រឹមត្រូវ ដោយយកទៅអភិវឌ្ឍន៍តំបន់សាធារណៈមានមន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន សាលារៀន សួនច្បារ ឬជាប្រាក់ខែប្រាក់បំណាច់ដល់មន្ត្រីរាជការនិងចាស់ព្រឹទ្ធាចារ្យជាដើម។ ជៀសវាងការប្រើប្រាស់ខ្ជះខ្ជាយ ឬការកិបកេងបន្លំយកមកធ្វើជាសម្បត្តិផ្ទាល់ខ្លួននិងបក្សពួកខ្លួន ។

១២.ឧស្សាហ៍ទៅសិក្សាស្រាវជ្រាវនិងសាកសួរដល់ពួកបណ្ឌិត ឬជំនាញឯកទេសជាពិសេសសមណព្រាហ្មណ៍មានព្រះភិក្ខុសង្ឃជាដើម ដែលជាអ្នកប្រព្រឹត្តល្អត្រឹមត្រូវតាមគន្លងសីល សមាធិ បញ្ញា នូវការណាអាក្រក់ ការណាល្អ គួរធ្វើ ឬមិនគួរធ្វើ មានប្រយោជន៍ឬគ្មាន ហើយអនុវត្តតាមឲ្យបានត្រឹមត្រូវ ។

## បច្ចេកទេសអភិវឌ្ឍន៍ខ្លួនឲ្យក្លាយជាមេដឹកនាំប្រកបដោយសមត្ថភាពខ្ពស់

ដើម្បីធ្វើខ្លួនឲ្យក្លាយទៅជាមនុស្សដែលមានភាវៈជាមេដឹកនាំ ហើយជាមេដឹកនាំដ៏មានសមត្ថភាព លទ្ធភាព និងប្រសិទ្ធិភាព គួរបដិបត្តិតាមគោលការណ៍ដែលហៅថា សប្បុរិសធម៌៧ គឺធម៌សំរាប់ជាគ្រឹស្ថានគាំទ្រដល់មនុស្សដែលមានបដិភាណ(flexibility) ទាំងឡាយ ។

១.យល់ទិសដៅនិងយល់ហេតុ គឺយល់គោលការណ៍និងច្បាប់នៃធម្មជាតិទាំងឡាយ ដែលខ្លួនមានទំនាក់ទំនងក្នុងការដំណើរជីវិត ក្នុងការបដិបត្តិនាទីនិងធ្វើកិច្ចការផ្សេងៗ។ យល់ដឹងរឿងដែលខ្លួនត្រូវប្រព្រឹត្តបដិបត្តិតាមហេតុផល ដូចជាយល់នូវតំណែង ឋានៈមុខរបរ ការងាររបស់ខ្លួន មាននាទីនិងទំនួលខុសត្រូវយ៉ាងណា មានអ្វីជាគោលការណ៍ និង ត្រូវធ្វើយ៉ាងណាទើបនឹងជាហេតុអោយបានទទួលបានផលសំរេច ទៅតាមនាទីនិងទំនួលខុសត្រូវទាំងអស់នោះជាដើម។ រហូតដល់កំរិតខ្ពស់បំផុត គឺយល់ច្បាស់ច្បាប់ធម្មតាឬសច្ចភាពនៃធម្មជាតិ ដើម្បីបដិបត្តិវាំងលោកនិងជីវិតយ៉ាងត្រឹមត្រូវ មានចិត្តគំនិតប្រកបដោយសេរីភាព មិនធ្លាក់ខ្លួនជាទាសកររបស់ជីវិត ។

២.យល់គោលបំណងនិងយល់ផល គឺយល់អត្ថន័យនិងទិសដៅនៃគោលការណ៍ ដែលខ្លួនបដិបត្តិ យល់វត្ថុបំណងដែលខ្លួនកំពុងធ្វើ ដឹងថាខ្លួនធ្វើដូច្នេះ ដំណើរជីវិតដូច្នេះ ដើម្បីសំដៅប្រយោជន៍អ្វីឬគួរនឹងបានផលដូចម្តេច។ ការដែលមាននាទី តំណែងឋានៈ ការងារយ៉ាងដូច្នេះ គេកំណត់ទុកដើម្បីបំណងអ្វី កិច្ចការដែលខ្លួនធ្វើខណៈនេះពេលធ្វើទៅហើយនឹងកើត

---

៤. *ធម្មញ្ញុតា (knowing principles, knowing causes)*, *អត្ថញ្ញុតា (knowing objectives, knowing results)*, *អត្តញ្ញុតា (knowing oneself)*, *មត្តញ្ញុតា (knowing moderation)*, *កាលញ្ញុតា (knowing occasion)*, *បរិសញ្ញុតា (knowing company)* និង *បុគ្គលញ្ញុតា (knowing persons)*

ផលអ្វីខ្លះ ជាផលល្អឬផលអាក្រក់ដូចនេះជាដើម។ រហូតដល់កំរិតខ្ពស់បំផុត គឺយល់អត្ថន័យនៃគំនិតយល់តាមហេតុពិតធម្មតា និងប្រយោជន៏ដែលជាទិសដៅសំខាន់បំផុតនៃជីវិត ។

៣.ស្គាល់ខ្លួនឯង គឺស្គាល់តាមសេចក្តីពិតថាខ្លួនយើងនោះបើចាត់ដោយឋានៈ ភាវៈ ភេទ កំឡាំង ចំណេះដឹង ជំនាញរបស់ខ្លួន សមត្ថភាពនិងគុណធម៌ជាដើម ឥឡូវនេះមានប៉ុន្មានយ៉ាងណា ហើយប្រព្រឹត្តបដិបត្តិអោយសមរម្យ និងធ្វើការផ្សេងៗអោយចុះសំរុងត្រឹមត្រូវតាមគោលការណ៏ នឹងបានជោគជ័យរហូតដល់ដោះស្រាយកែប្រែខ្លួនអោយចំរើនលូតលាស់សំបូរសប្បាយកាន់តែខ្លាំងឡើង ។

៤.ចេះប្រមាណ គឺចេះស្គាល់ល្មមដូចជាចេះប្រមាណក្នុងការបរិភោគរឿងការចាយវាយទ្រព្យ ស្គាល់ភាពគួរពុំគួរក្នុងការនិយាយ ការបដិបត្តិកិច្ចការ និងការងារផ្សេងៗរហូតដល់ការសំរាកលំហែកាយ និងការីករាយភ្លើតភ្លើនទាំងឡាយ។ ធ្វើការគ្រប់យ៉ាងដោយយល់ច្បាស់នូវវត្ថុបំណង ដើម្បីលទ្ធផលល្អដែលចង់បាន មិនគ្រាន់តែដើម្បីសេចក្តីពេញចិត្ត ចូលចិត្តឬយកតែចិត្តខ្លួនឯង តែត្រូវធ្វើអោយសមល្មមដល់ហេតុបច្ច័យឬកត្តាប្រកបទាំងឡាយ ដែលនិងចុះសំរុងអោយកើតផលល្អតាមដែលច្ចុះបញ្ចាំងដោយបញ្ញា ។

៥.ដឹងកាល គឺដឹងកាលវេលាដែលសមរម្យនិងរយៈពេលដែលប្រើប្រកបនាទីកិច្ចការផ្សេងៗ និងការទំនាក់ទំនងជាមួយអ្នកដទៃ ដោយដឹងថាពេលណាគួរធ្វើអ្វី ធ្វើយ៉ាងណា និងធ្វើអោយត្រង់វេលា អោយកើតវេលា អោយទាន់វេលា អោយល្មមគួរសមដល់វេលា អោយត្រូវវេលា រហូតដល់ចេះបែងចែកវេលា និងកំណត់គំរោងការប្រើពេលវេលាអោយបានផល ។

៦.ស្គាល់ទីប្រជុំជន គឺស្គាល់ទឹកដី ស្គាល់ទីជុំនំ និងជុំជន ស្គាល់ការគួរប្រព្រឹត្តបដិបត្តិនៅទីជុំនំនិងជុំជននោះៗថា ជុំជននោះពេលចូលទៅប្រាស្រ័យទាក់ទងគួរធ្វើអាកប្បកិរិយាយ៉ាងនេះ គួរនិយាយយ៉ាងនេះ ជុំជននេះមានរបៀបយ៉ាងនេះ មានវប្បធម៌ប្រពៃណីយ៉ាងនេះ មានសេចក្តីត្រូវការយ៉ាងនេះ គួរទំនាក់ទំនង គួរជួយសង្រ្គោះ គួរជួយដោះធុរៈ គួរបំពេញប្រយោជន៏អោយយ៉ាងនេះ។ ជាដើម ។

៧.ស្គាល់បុគ្គល គឺស្គាល់និងយល់នូវភាពខុសប្លែកគ្នានៃបុគ្គល ដូចជាអធ្យាស្រ័យ សមត្ថភាពនិងគុណធម៌ជាដើម នរណាតឹងតែងឬធូររលុងយ៉ាងណា។ ចេះវិធីដិបត្តិដល់បុគ្គលផ្សេងៗអោយល្អថា គួរនិងសេពគប់ឬទេ អាចទទួលបានគំនិតអ្វីពេលចងសម្ព័ន្ធជាមួយ អាចច្នៃប្រើ ហើយគួរលើកសរសើរ, ទិតៀន ឬណែនាំប្រៀនប្រដៅយ៉ាងណាទើបបានផលល្អ ជាដើម ។

## ត្រូវប្រគល់ខ្លួនឲ្យបានជាទីពឹងសំរាប់អ្នកដទៃដោយបានសាងទីពឹងឲ្យខ្លួនឯងរួចហើយ

ជាការពិតណាស់មេដឹកនាំត្រូវមានគោលជំហររឹងមាំប្រកបដោយចំណេះដឹង និង ចំណេះធ្វើ ដែលចំណេះនេះកើតឡើងពីការប្រឹងប្រែងព្យាយាមដោយខ្លួនឯង ជាការសាង ខ្លួនឯងឲ្យបានជាកោះដ៏មានប្រយោជន៍ ហៅថានាថករណធម៌[៥] ១០ យ៉ាង គឺ

១.បដិបត្តិល្អមានវិន័យនិងសីលធម៌ គឺដំណើរជីវិតដោយសុចរិតទាំងផ្លូវកាយ ផ្លូវវាចា មានសុជីវធម៌ និងប្រកបសម្មាអាជីវៈ ។

២.បានសិក្សាត្រងត្រាប់មកច្រើន គឺត្រងត្រាប់ស្តាប់និងសិក្សារៀនសូត្រមកច្រើន ច្បុចយកមួយណាដែលជាវិជ្ជាជីវៈរបស់ខ្លួនឬខ្លួនសិក្សាសិល្បៈវិជ្ជាមួយណាដោយសិក្សាអោយ ជាក់ច្បាស់យល់ដឹងអោយទូលំទូលាយជ្រាលជ្រៅ ចេះយ៉ាងច្បាស់លាស់និងអាចប្រើការបាន។

៣.ចេះសេពគប់មនុស្សល្អ គឺមានកល្យាណមិត្ត ចេះរើសរកសេវនាចូលទៅរកគណៈទីប្រឹក្សា និងអ្នកណែនាំជាស់តៀនដែលមានសមត្ថភាព ចូលជិតស្និទ្ធ និងយកតំរាប់តាម បរិដ្ឋានសង្គមជុំវិញដែលល្អ និងញុំាងជីវិតអោយចំរើនលូតលាស់ល្អ ។

---

*៥.សីល*(good conduct), *ពាហុសច្ច*(great learning), *កល្យាណមិត្តា*(good company), *សោវចស្សតា*(meekness), *កឹ ករណីយេសុ ទក្ខ*(willingness to give a helpful hand), *ធម្មកាមតា*(love of truth), *វីរិយារម្ភ*(energetic exertion), *សន្តុដ្ឋិ*(contenment), *សតិ*(mindfulness) *និង បញ្ញា*(insight)

៤.ជាមនុស្សដែលងាយនិយាយគ្នា គឺមិនរឹងត្អឹង ចេះស្តាប់ហេតុផល និងសេចក្តីពិត ត្រៀមនឹងកែប្រែដុសជំរៈខ្លួនឯងទៅតាមតថភាពជាក់ស្តែង ។

៥. ខ្វល់ខ្វាយនូវកិច្ចការរបស់ពួកនិងក្រុម គឺយកចិត្តទុកដាក់ ជួយដោះធុរៈ និងកិច្ចការរបស់អ្នករួមក្រុមជាមួយ មានញាតិមិត្តនិងបុគ្គលិករួមការងារ ចេះប្រើបញ្ញាពិចារណារកវិធីដំណើរការដែលសមរម្យ ធ្វើកើត ចាត់ចែងអោយបានសំរេចជាស្ថាពរ ។

៦.ជាអ្នកប្រាថ្នានូវធម៌ គឺស្រលាញ់ព្រះធម៌ ចូលចិត្តការសិក្សា ស្រាវជ្រាវ ចេះសាកសួរស្វែងរកចំណេះដឹង រកសេចក្តីពិត ចេះនិយាយ ចេះស្តាប់ សាងអារម្មណ៏រស់រាយសប្បាយចិត្ត ធ្វើអោយអ្នកដទៃចង់ចូលមកប្រឹក្សារួមសេវនានិងសន្ទនាជាមួយ ។

៧.មានសេចក្តីឧស្សាហ៏ព្យាយាម គឺព្យាយាមលះចោលសេចក្តីអាក្រក់ ប្រព្រឹត្តតែសេចក្តីល្អ ពុះពារឈានទៅមុខ មិនរាថយ មិនបោះបង់ចោលនូវតួនាទីខ្លួន ។

៨.ចេះប្រមាណមានសន្តោស គឺរីករាយពេញចិត្តតែក្នុងលាភសក្ការៈ លទ្ធផលនិងផលសំរេចផ្សេងៗ ដែលខ្លួនបានធ្វើឬស្វែងរកមកបានដោយកំឡាំងឧស្សាហ៏ព្យាយាមរបស់ខ្លួនឯង ប្រកបដោយធម៌ហើយមិនវង្វេងវង្វាន់មើលឃើញតែសេចក្តីសុខផ្នែកវត្ថុតែម៉្យាង ។

៩. ភ្ញាក់រលឹកជាប់ជានិច្ចគឺចេះកត់ចំណាំទុក នឹកដល់ទង្វើដែលបានធ្វើ សំដីដែលបានធ្លាប់និយាយ ការងារដែលធ្វើហើយនិងនៅមិនទាន់ធ្វើ ធ្វើបានល្អិតល្អន់ ចេះថ្លឹងថ្លែងចិត្តមិនស្រពេមស្រពាម ។

១០. មានបញ្ញាជាប់ក្នុងអារម្មណ៏ គឺមានបញ្ញាយល់ដឹងហេតុផល ដឹងអាក្រក់ដឹងល្អ គុណនិងទោស មានប្រយោជន៏និងគ្មានប្រយោជន៏ មើលឃើញរឿងរ៉ាវទាំងឡាយតាមសភាវៈពិតរបស់វា ចេះគិតពិចារណាវិនិច្ឆ័យដោយចិត្តដែលឯករាជ្យ ធ្វើកិច្ចការផ្សេងៗប្រកបដោយគំនិត និងមានវិចារណញាណ ។

## មន្តស្នេហ៍របស់មេដឹកនាំ

ត្រូវមានសន្តានចិត្តរស់នៅជាមួយគ្នាយ៉ាងស្ងប់សុខ មានសម្ព័ន្ធភាពស្អិតរមួតជាមួយអ្នកដទៃ ជាពិសេសមិត្តរួមកិច្ចការ ឬរួមសហគមន៍ រហូតដល់បងប្អូនក្នុងក្រុមគ្រួសារ គួរបដិបត្តិតាមគោលធម៌នៃការរស់នៅរួមគ្នា ដែលហៅថា សារាណិយធម៌[៦] (ធម៌ជាហេតុនាំអោយនឹករលឹកដល់គ្នា) ៦ ប្រការគឺ :

១.បដិបត្តិរវាងគ្នានិងគ្នាដោយមេត្តា គឺសំដែងមេត្រីភាព និងក្តីប្រាថ្នាល្អដល់មិត្តរួមការងារ រួមកិច្ចការ រួមសហគមន៍ ជួយដោះកិច្ចធុរៈផ្សេងៗដោយក្តីពេញចិត្ត សំដែងអាកប្បកិរិយាសុភាព គោរពរាប់អានទាំងនៅចំពោះមុខនិងនៅពីក្រោយខ្នង ។

២.និយាយសាសង់គ្នាដោយមេត្តា គឺជួយពន្យល់ប្រាប់រឿងដែលជាប្រយោជន៍ ប្រៀនប្រដៅឬដាស់តឿនណែនាំគ្នាដោយសេចក្តីប្រាថ្នាល្អ ពោលវាចាសុភាពទន់ភ្លន់ សំដែងសេចក្តីគោរពរាប់អានប្រកបដោយភាពស្មោះស្ម័គ្រ ។

៣.គិតនិងនឹករលឹកដល់គ្នាប្រកបដោយមេត្តា គឺតាំងចិត្តប្រាថ្នាល្អ គិតធ្វើអ្វីដែលជាប្រយោជន៍ដល់គ្នា មើលឃើញគ្នាក្នុងលក្ខណៈដែលល្អ មានមុខមាត់ញញឹមញញែមដាក់គ្នា

៤.បានអ្វីមកក៏បែងចាំនចែកគ្នា គឺបែងចាំនលាភសក្ការៈដែលបានមកដោយយុត្តិធម៌ ទោះបីជារបស់តិចតួច ក៏បែងចែកជាភាគៗ អោយបានយកទៅបរិភោគប្រើប្រាស់គ្រប់ៗគ្នា។

៥.ប្រព្រឹត្តអោយល្អដូចគេ គឺមានសេចក្តីប្រព្រឹត្តសុចរិតល្អប្រពៃ រក្សារបៀបវិន័យ មិនធ្វើខ្លួនអោយក្លាយជាទីស្អប់ខ្ពើម ឬខូចអន្តរាយដល់ក្រុមបក្សពួក ។

៦.បញ្ច្រាបសេចក្តីយល់ឃើញឲ្យរលាយចូលគ្នាបាន គឺគោរពស្តាប់សេចក្តីគិតឃើញ

---

*៦.មេត្តាកាយកម្ម(friendly action) , មេត្តាវចីកម្ម(friendly speech) , មេត្តាមនោកម្ម(friendly thought) , សាធារណភោគី(sharing of gains) , សីលសាមញ្ញតា(moral harmony) , ទិដ្ឋិសាមញ្ញតា(harmony of views) ។*

វាងគ្នា យល់ឃើញរួមគ្នា យល់ព្រមគ្នាបានក្នុងគោលការណ៍សំខាន់ៗ ប្រកាន់យកឧត្តមគតិនៃសេចក្តីល្អ ឬគោលដៅរួមគ្នាខ្ពស់បំផុត ។

## មេដឹកនាំត្រូវឆ្លាតក្នុងការគ្រប់គ្រងអង្គការមហាជន

ឆ្លាតវាងវៃក្នុងការគ្រប់គ្រង ដោយបដិបត្តិតាមគោលនៃការទទួលខុសត្រូវរួមគ្នា ដែលនិងជួយការពារសេចក្តីវិនាសហិនហោច នាំមកនូវសេចក្តីចំរើនរុងរឿង ដោយហៅថា អបរិហានិយធម៌ ៧ ប្រការគឺ :

១.ឧស្សាហ៍ប្រជុំគ្នាជាប្រចាំ ជួបជុំប្រឹក្សាដេញដោលការងារដែលនឹងទទួលខុសត្រូវតាមឋានៈរបស់ខ្លួនជាប្រចាំ ។

២.ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាឈប់ប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចការទាំងឡាយដែលនឹងត្រូវធ្វើរួមគ្នា ។

៣.មិនធ្វើតាមអំពើចិត្តគិតតែស្រណុកសប្បាយ ដាក់បញ្ញត្តិរបៀបវិធីផ្សេងៗដែលនៅមិនទាន់ចុះកិច្ចព្រមព្រៀងបញ្ញត្តិទុក និងមិនដាន់ឈ្លីប្រព្រឹត្តល្មើសលើរឿងដែលបានបញ្ញត្តិទុករួចហើយ បដិបត្តិអោយជាក់លាក់ក្នុងបទបញ្ញត្តិធំៗណាដែលកំណត់ដោយច្បាប់រដ្ឋធម្មនុញ្ញ ។

៤.បុគ្គលណាដែលជាអាវុសោ មានបទពិសោធន៍យូរយារ គួអោយកិត្តិយសគោរពរាប់អានបុគ្គលទាំងអស់នោះ មើលឃើញភាពសំខាន់នៃពាក្យសំដីរបស់ពួកគាត់ថា ជាពាក្យសំដីដែលយើងគួរស្តាប់និងយកគំរាប់តាម ។

៥.ផ្តល់កិត្តិយស និងការពារកុលស្ត្រី មិនអោយមានការមើលងាយមើលថោកដល់ស្ត្រីភេទទាំងឡាយ ។

៦.គោរពបូជាសក្ការៈចេតិយ៍ បូជនីយដ្ឋាន អនុសាវរីយ៍ជាតិ ដែលជាវត្ថុក្រើនរំលឹក

នូវក្តីចង់ចាំ ពញ្ញាក់អោយធ្វើសេចក្តីល្អ និងជាទីរួមចិត្តរួមថ្លើមរបស់សមាជិកក្នុងសង្គម មិនប្រងើយកន្តើយក្នុងការគោរពបូជាដែលគួរនឹងធ្វើចំពោះស្ថានអនុស្សាវរីយ៍ទាំងអស់នោះតាមប្រពៃណី ។

៧.ចាត់កិច្ចការពាររក្សា ទំនុកបំរុង ការពារ ប្រកបដោយធម៌ ដល់បព្វជិតអ្នកមានសីលមានធម៌បរិសុទ្ធិ ដែលជាទីប្រជុំផ្លូវចិត្ត និងជាទីគំរូផ្នែកសីលធម៌របស់ប្រជាជន ទទួលរាក់ទាក់ដោយក្តីពេញចិត្ត និងប្រាថ្នាអោយបព្វជិតទាំងអស់រស់នៅប្រកបដោយសេចក្តីស្ងប់សុខ ។

## ពន្លឺរស្មីនៃជីវិតសំរាប់ភាវៈជាមេដឹកនាំ

មនុស្សដែលត្រូវគេហៅថាអ្នកដឹកនាំ គឺជាអ្នកហ្វឹក អ្នកសិក្សា និងអ្នកអភិវឌ្ឍន៍ខ្លួនឯង ជាពិសេសទំពាំងស្នងឫស្សី ឬយុវជនជំនាន់ក្រោយ ដែលជាសមាជិកថ្មីរបស់មនុស្សជាតិ គួរមានគុណសម្បត្តិសំរាប់ជាទុន៧[៧] ប្រការហៅថាពន្លឺមាសពន្លឺប្រាក់នៃជីវិតដ៏ឧត្តម ឬរស្មីងអរុណរះនៃការសិក្សា ដែលជាឧបករណ៍លើកស្ទួយជីវិតឈានទៅរកសេចក្តីចំរើន ដើម្បីអោយក្លាយជាមេដឹកនាំសង្គមដ៏ប្រសើរពិតប្រាកដ ដូចតទៅនេះគឺ

១.មានកល្យាណមិត្ត ស្វែងរកប្រភពបញ្ញានិងគំរូល្អៗ ដោយនៅជិតស្និតជាមួយកល្យាណជន ផ្តើមតាំងតែឳពុកម្តាយជាកល្យាណមិត្តក្នុងគ្រួសារ។ ចេះសេពគប់បុគ្គល និងចូលក្នុងសង្គមវិញ្ញូជន អាចនិងមានឥទ្ធិពលអូសទាញនាំគ្នីគ្នាទៅរកភាពចំរើនលូតលាស់ក្នុងការផ្លាស់ប្តូរព្រត្តិកម្ម ចិត្តគំនិត និងសតិបញ្ញា ជាពិសេសបានរៀនសូត្រនិងអភិវឌ្ឍការទំនាក់ទំនងនិងសម្ព័ន្ធភាពជាមួយមិត្តមនុស្សដោយមេត្តា។ មានសេចក្តីជឿជាក់ ដើរតាម

---

*៧.កល្យាណមិត្តា(having a good friend), សីលសម្បទា(perfection of morality), ឆន្ទសម្បទា (perfection of aspiration), អត្តសម្បទា(perfection of oneself), ទិដ្ឋិសម្បទា(perfection of view), អប្បមាទសម្បទា(perfection of heedfulness), យោនិសោមនសិការ(perfection of wise reflection) ។*

គុំល្អៗនិងចេះប្រើបច្ច័យខាងក្រៅ ទាំងបុគ្គល ទាំងតំរាឯកសារ និងប្រព័ន្ធផ្សព្វផ្សាយទាំងឡាយអោយបានជាប្រយោជន៏ក្នុងការស្វែងរកចំណេះដឹង និងសេចក្ដីល្អ ដើម្បីនាំមកបំរើការក្នុងការអភិវឌ្ឍន៏ជីវិត ដោះស្រាយបញ្ហានិងការសាងប្រយោជន៏សង្គម ។

២.រក្សានិងអភិវឌ្ឍន៏វិន័យនិងសីលធម៌ ដែលជាឫសគល់នៃការអភិវឌ្ឍន៏ជីវិតនិងសង្គម គឺចេះចាត់របៀបការរស់នៅ ការងារ និងបរិដ្ឋានអោយសមស្របដល់ការអភិវឌ្ឍន៏ជីវិតយ៉ាងហោចណាស់មានសីលធម៌ជាមូលដ្ឋាន មានកិច្ចសហការត្រឹមត្រូវក្នុងការមានទំនាក់ទំនងជាមួយបរិដ្ឋានសង្គមដោយការរស់នៅជាមួយមិត្តមនុស្សយ៉ាងអត់ធន់ អនុគ្រោះ មិនបៀតបៀនគ្នា។ ចំណែកសម្ព័ន្ធភាពវាងបរិដ្ឋានវត្ថុដូចជាការបរិភោគបច្ច័យ៤ រហូតដល់ឧបករណ៏អេឡិចត្រូនិចទាន់សម័យទាំងឡាយ ប្រើប្រាស់ក្នុងផ្លូវនៃការទំនុកបំរុងគុណភាពជីវិត ទ្រទ្រង់ការសិក្សាសាងភាពចំរុងចំរើន និងប្រព័ន្ធតុល្យភាពរបស់ធម្មជាតិ ។

៣.ញុំាំងឆន្ទៈអោយបរិបូរ មានចិត្តគំនិតស្វះស្វែងរកក្ដីចំរុងចំរើនគឺជាអ្នកមានកំឡាំងសមត្ថភាពចង់ចេះ ចង់ដឹង ចង់ល្អ ខំប្រឹងធ្វើការ ចង់បានភាពចំរុងចំរើន ចង់បានសំរេចចង់បានខ្ពង់ខ្ពស់ ចង់ជួយគ្រប់គ្នាដែលខ្លួនជួបប្រទះ មានសហប្រតិបត្តិការជាមួយ នាំទៅរកសភាពល្អប្រពៃរ៏ មិនវង្វេងជាប់ជំពាក់ក្នុងគំនិតដែលគិតតែចង់បាន និងមិនស្វែងរកសេចក្ដីសុខដែលបានពីការសេពបរិភោគហួសប្រមាណ ធ្វើឲ្យលង់វង្វេងក្នុងអន្លង់នៃការស្រវឹងផោកង៉ុយនិងការប្រកួតប្រជែងប្រកបដោយមហិច្ឆិតា។ តែចេះតំរង់ឥន្ទ្រីយ៏ មានភ្នែកដើម្បីមើល ត្រចៀកដើម្បីស្ដាប់ជាដើម ក្នុងការសិក្សារៀនសូត្ររកសេចក្ដីចំរើន និងមានសេចក្ដីសុខពីការបានធ្វើសេចក្ដីល្អដែលកើតពីការប្រើខួរក្បាលនិងអវយវៈរបស់ខ្លួន ។

៤. បំពេញខ្លួនឲ្យបរិបូរមុតមាំ ហ្វឹកខ្លួនឲ្យអស់ពីទំហឹងរហូតដល់ភាពពិតជាមនុស្សឈានចូលមកដល់ គឺរលឹកដល់ជារហូតនូវសភាពពិតនៃធម្មជាតិរបស់មនុស្ស ដែលជាសត្វអាចបង្វឹកបានហើយត្រូវតែបង្វឹកឲ្យបានប្រសើរឧត្ដមបំផុតទាំងកាយទាំងចិត្ត។ ហ្វឹកខ្លួនរហូតមើលឃើញសេចក្ដីទុក្ខលំបាក ឧបសគ្គ និងបញ្ហាផ្សេងៗប្រៀបប្រដូចនឹងវេទិការធ្វើការ

ពិសោធន៍ និងអភិវឌ្ឍន៍សមត្ថភាពសតិបញ្ញា មានសេចក្តីភ្ញាក់រលឹកក្នុងការអភិវឌ្ឍន៍ខ្លួនអោយខ្ពស់ឡើងរហូតដល់នូវសុពលភាពដែលជាគ្រឹះអភិវឌ្ឍន៍គ្រប់ផ្នែកទាំងអស់ ទាំងវិរិត្តិកម្មចិត្តគំនិត និងសតិបញ្ញា ។

៥.ញ៉ាំងទិដ្ឋិឲ្យបរិបូរ ប្រកាន់ខ្ជាប់នូវហេតុបច្ច័យ សំឡឹងមើលអ្វីៗប្រកបដោយហេតុនិងផលគឺតាំងខ្លួននៅក្នុងផ្នត់គំនិតការជឿជាក់ដែលល្អប្រពៃមានហេតុផល យ៉ាងហោចណាស់ប្រកាន់យកធម៌នៃហេតុបច្ច័យដែលនឹងនាំទៅរកការពិចារណាត្រិះរិះត្រឹមត្រូវ។ ស្រាវជ្រាវរាវរកផ្នត់គំនិតដែលជាផ្លូវចំរើនខាងបញ្ញា និងជឿលើការប្រព្រឹត្តថាជាអំណាចធំបំផុតដែលធ្វើឲ្យជោគវាសនាព្រមទាំងចិត្តគំនិតស្ថិតនៅក្នុងភាពត្រឹមត្រូវនិងរីកចំរើន ។

៦.ញ៉ាំងសេចក្តីមិនប្រមាទឲ្យបរិបូរស្ថិតនៅក្នុងខ្លួន គឺមានចិត្តភ្ញាក់រលឹកក្នុងសេចក្តីមិនទៀង មើលឃើញឲ្យច្បាស់នូវភាពមិននៅមួយកន្លែង មិនធន់នៅ និងមិនគង់វង្សទាំងជីវិតនិងវត្ថុទាំងឡាយជុំវិញខ្លួនយើង ដែលផ្លាស់ប្តូរទៅតាមហេតុបច្ច័យទាំងខាងក្នុងនិងខាងក្រៅគ្រប់ពេលវេលា ធ្វើឲ្យសម្ងំស្ងៀមមិនបាន ហើយមើលឃើញតំលៃដ៏សំខាន់នៃពេលវេលា ហើយគួរប្រញាប់ប្រញាល់ស្វែងរកការសិក្សានិងដោះស្រាយការពារហេតុបច្ច័យអាក្រក់ទាំងឡាយ និងរក្សាទំនុកបំរុងហេតុបច្ច័យដែលនាំទៅរកសេចក្តីចំរើនថ្មុំថ្មើង ដោយប្រើពេលវេលាទាំងយប់ទាំងថ្ងៃដែលកន្លងផុតទៅ ឲ្យបានជាប្រយោជន៍ច្រើនបំផុត ។

៧.ញ៉ាំងយោនិសោមនសិការឲ្យបរិបូរ គឺឆ្លាតក្នុងគិតពិចារណាស្វែងយល់ឲ្យបាននូវប្រយោជន៍និងសេចក្តីពិត គឺចេះគិត ចេះពិចារណា យល់ត្រូវ គិតត្រូវ ឃើញវត្ថុទាំងឡាយតាមសភាវៈពិតរបស់វា ដែលសមនឹងហេតុបច្ច័យដោយប្រើបញ្ញាពិចារណាស្រាវជ្រាវ រាវរករិះគិត ដោះស្រាយបញ្ហានិងវិធីដំណើរការផ្សេងៗឲ្យបានសំរេចបានដោយវិធីការប្រើបញ្ញាដែលអាចធ្វើជាទីពឹងខ្លួនឯងនិងអ្នកដទៃបាន ។

## បញ្ញត្តិ១០យ៉ាងសំរាប់មេដឹកនាំ

ដើម្បីអភិវឌ្ឍខ្លួនឲ្យទៅជាមេដឹកនាំពេញលក្ខណះបរិបូរ និងមានតេជានុភាពពេញលេញ បុគ្គលត្រូវអនុវត្តតាមបញ្ញត្តិ១០[៨]យ៉ាងនេះឲ្យបានជាក់លាក់

១.ធ្វើទានចែករំលែកដល់ប្រជាជន គឺបំពេញខ្លួនជាអ្នកអោយ ដោយសំដៅការគ្រប់គ្រងឬធ្វើការដើម្បីគេបានមិនមែនដើម្បីយកពីគេវិញទេ។ យកចិត្តទុកដាក់ចូលទៅបំរើការចាត់ចែងសង្គ្រោះ អនុគ្រោះ អោយប្រជានុរាស្ត្របានទទួលប្រយោជន៏សុខ មានភាពសុខស្រួលប្រាសចាកភ័យ រហូតដល់ផ្តល់ការឧបត្ថម្ភដល់អ្នកដែលទទួលរងទុក្ខវេទនាហើយផ្តល់ការគាំទ្រដល់បុគ្គលដែលធ្វើសេចក្តីល្អ។ ការធ្វើទានមិនមែនសំដៅទៅលើការដើរចែកមីកញ្ចប់សំពត់ស ក្រមាជាដើមដែលជាអំណោយបន្តិចបន្តួចនោះទេ តែជាការផ្តល់ការអប់រំបញ្ចៀសពួកគេឲ្យគេចផុតពីគ្រោះល្ងង់ខ្លៅ បង្កើតទីផ្សារការងារ និងសមភាពនៃជីវិតក្រោមដំបូលច្បាប់តែមួយ ។

២.រក្សាភាពសុចរិត គឺប្រព្រឹត្តល្អ សង្រួមកាយទ្វារ វចីទ្វារ ប្រកបតែសុចរិតភាព រក្សាកិត្តិយស ប្រព្រឹត្តអោយសមជាគំរូ ជាទីគោរពរាប់អានរបស់ប្រជានុរាស្ត្រ មិនឲ្យមានចំណុចណាដែលអ្នកដទៃមើលងាយមើលថោកបាន ។

៣.បំពេញកិច្ចដោយការលះបង់ គឺអាចលះបង់សេចក្តីសុខសំរាន្តរហូតដល់ជីវិតរបស់

---

*៨. ទាន(sharing with the populace) , សីល(maintaining good conduct) , បរិច្ចាគ.(working selflessly) , អាជ្ជវ.(working honestly) , មទ្ទវ.(deporting himself with gentleness and congeniality) , តប.(rejecting indulgence through austerity) , អក្កោធ.(adhering to reason, not anger) , អវិហិង្សា(bringing tranquility through non-violence) , ខន្តិ(overcoming difficulty with patience) , អវិរោធន.(not doing that which strays from righteousness)*

ខ្លួនជាដើម ដើម្បីប្រយោជន៍សុខរបស់ប្រជាជន និងសេចក្តីស្ងប់ស្ងាត់មានរបៀបរបស់ប្រទេសជាតិ ។

៤.បដិបត្តិភារកិច្ចដោយស្មោះត្រង់ គឺស្មោះត្រង់ជឿជាក់ឥតក្លែងក្លាយ បដិបត្តិភារកិច្ចដោយសុចរិត មានសេចក្តីទៀងត្រង់មិនបោកប្រាស់ប្រជាជន ។

៥.សុភាពទន់ភ្លន់ជាទីចង់ប្រាស្រ័យទាក់ទងពីអ្នកដទៃ គឺមានអធ្យាស្រ័យ មិនក្រអឺតក្រទម វាយឫកពារ ប្រកាន់ខ្លួន មានទឹកមុខស្ងួស្រស់បស់ចេញពីអាកប្បកិរិយាសុភាពទន់ភ្លន់ គួរជាទីស្រលាញ់ គោរពកោតក្រែង ដោយមិនមែនកើតពីការខ្លាចញញើតទេ ។

៦. បេញខ្លួនផុតពីក្តីវង្វេងភ្លើតភ្លើនដោយការដុតកំដៅកិលេសគឺដុតបំផ្លាញកិលេសតណ្ហាមិនអោយចូលមកគ្របសង្កត់ចិត្ត ទប់បង្អាក់សង្កត់ចិត្តបាន មិនវង្វេងវង្វាន់លង់លក់ក្នុងកាមសុខនិងការបំរើផ្គាប់ផ្គុន មានជីវិតរស់នៅយ៉ាងប្រក្រតី ឬរស់នៅយ៉ាងសាមញ្ញ គិតតែនឹងព្យាយាមបំពេញមុខនាទីអោយពេញលេញ ។

៧.យកហេតុផលជាធំ មិនមែនយកកំហឹងទល់កំហាល់ គឺមិនក្រេវក្រោធ មិនវិនិច្ឆ័យសេចក្តីឬប្រតិបត្តិការដោយអំណាចនៃកំហឹងមោហៈ។ មានមេត្តាប្រចាំចិត្តទុកបង្រ្កាបសេចក្តីក្រេវក្រោធ វិនិច្ឆ័យសេចក្តីនិងប្រតិបត្តិការដោយចិត្តត្រជាក់ ត្រិះរិះប្រកបដោយធម៌ ។

៨.មានអហិង្សភាព នាំមកនូវភាពត្រជាក់ត្រជុំ គឺមិនឈ្លក់វង្វេងទៅតាមអំណាចមិនសង្កត់សង្កិនបង្ខិតបង្ខំ មានសេចក្តីអាណិតអាសូរ មិនរកហេតុបៀតបៀនដាក់ទោសទណ្ឌកម្មដល់ប្រជានុរាស្រ្តណាម្នាក់ ដោយអាស្រ័យសេចក្តីស្អប់ខ្ពើម គុំនំគុំគួន ។

៩.យកឈ្នះក្តីលំបាកដោយខន្តី គឺអត់ធន់ដល់ការងារធំៗលំបាកៗ អត់ធន់មិនខ្លាចសេចក្តីលំបាកនឿយហត់ ទោះបីលំបាកកាយ នឿយហត់យ៉ាងណា ក៏មិនរាថយ ទោះបីត្រូវញុះញង់ដោយពាក្យបុករុកចាក់ដោតយ៉ាងណា ក៏មិនអស់កំលាំងចិត្ត មិនព្រមលះបង់ករណីយកិច្ច ដែលប្រកបដោយធម៌ ។

១០.មិនបដិបត្តិឃ្លៀងឃ្លាតពីធម៌ គឺបដិបត្តិមិនអោយខុសពីព្រះសាសនធម៌ ដែល

ប្រកាន់យកប្រយោជន៏សុខ សេចក្ដីល្អត្រឹមត្រូវរបស់រដ្ឋ និងប្រជានុរាស្ត្រជាគោលដៅ។ រឿងណាប្រជានុរាស្ត្រប្រាថ្នាយ៉ាងត្រឹមត្រូវ នឹងមិនហាមប្រាម។ កិច្ចការណាប្រកបដោយធមិ ដើម្បីប្រយោជន៏សុខរបស់ប្រជាជន នឹងមិនរារាំង ដាក់ខ្លួនអោយមុឹងម៉ាត់ក្នុងគោលធមិ និតិធមិ ដែលជារបៀបរៀបរយក្នុងការគ្រប់គ្រងរហូតដល់ទំនៀមទំលាប់ ប្រពៃណីដ៏ល្អប្រសើរ មិន ប្រព្រឹត្តអោយជ្រុលជ្រួសខុសឆ្គងខូចបង់ដោយប្រការណាឡើយ ។



# សៀវភៅអានប្រកប


- ព្រហ្មវិហារធម៌, ទីឃនិកាយ, មហាវគ្គ, ព្រះសុត្តន្តបិដក
- អរិយសច្ច ៤, សំយុត្តនិកាយ, មហាវគ្គ, សុត្តន្តបិដក
- អដ្ឋង្គិកមគ្គ, ទីឃនិកាយ, មហាវគ្គ, សុត្តន្តបិដក
- សប្បុរសធម៌៧, ទីឃនិកាយ, បាដិកវគ្គ, សុត្តន្តបិដក ១៩.២០២.២១១
- នាថករណធម៌១០, ទីឃនិកាយ, បាដិកវគ្គ, សុត្តន្តបិដក ១៩.២២៨.២៤២-២៤៦
- ចក្រពត្តិធម៌១២ ទីឃនិកាយ, បាដិកវគ្គ, សុត្តន្តបិដក
- សង្គហវត្ថុ៤ អង្គុត្តរនិកាយ, ចតុក្កនិបាត, សុត្តន្តបិដក
- រាជសង្គហវត្ថុ៤ អង្គុត្តរនិកាយ, ចតុក្កនិបាត, សុត្តន្តបិដក
- សារាណិយធម៌៦ ទីឃនិកាយ, បាដិកវគ្គ, សុត្តន្តបិដក ២៩.១៨៨.១៩៦-១៩៨
- អបរិហានិយធម៌ ៧, ទីឃនិកាយ, មហាវគ្គ, សុត្តន្តបិដក
- រាជធម៌ឬទសពិតរាជធម៌១០, ខុទ្ទកនិកាយ, ជាតក, សុត្តន្តបិដក

*<u>សំគាល់:</u>* ១៩.២០២.២១១ មានន័យថា ព្រះត្រៃបិដកក្បាលទី១៩, វគ្គទី២០២ និង ទំព័រ២១១

- ធម្មនុញ្ញជីវិត, ព្រះធម្មបិដក(បកប្រែដោយព្រះភិក្ខុផាទានោ សេង សុភ័ណ), បាងកក ព.ស.២៥៤៦, គ.ស.២០០២
- វចនានុក្រមខ្មែរ ភាគ១-២, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ព.ស.២៥១២, គ.ស.១៩៦៧
- ព្រះបាទធម្មិក, ឥន្ទបញ្ញោ ហ.មណីចិន្តា, អន្លង់វិល, គ.ស.១៩៩៥
- Dictionary of Buddhism, Dhammapitaka, Bangkok, B.E.2538